**សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ**

**និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

**សារណាបញ្ចប់ការសិក្សា**

# ការចូលរួមរបស់វិស័យទេសចរណ៍ក្នុង កំណើនសេដ្ឋកិច្ចជាតិ

ចុះស្រាវជ្រាវពីថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៧ ដល់ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០១៧

តាក់តែងដោយៈ

និស្សិតឈ្មោះ **ឯក ស្រីឡែន**

**សូ លីណា**

ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាន់ទី១៦

ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍

សាស្ត្រាចារ្យណែនាំៈ

បណ្ឌិត **ខ៉ាន់ ស៊ុនដេត**

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

ក្នុងនាមយើងខ្ញុំទាំងពីរនាក់ ឯក ស្រីឡែន និង សូ លីណា ជានិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ ក្រុម $E_4DA_1$ និង $E_4DC_1$ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖

អ្នកមានគុណទាំងពីរ ដែលបានខិតខំចិញ្ចឹមបីបាច់ថែរក្សា ទំនុកបំរុងលើការរស់នៅ ការសិក្សា ប្រៀនប្រដៅកូនឲ្យកូនក្លាយទៅជាមនុស្សល្អក្នុងសង្គម ព្រមទាំងផ្តល់នូវកម្លាំងកាយ និង កម្លាំងចិត្តដល់កូន។

លោកសាស្ត្រាចារ្យបណ្ឌិត ង៉ាន់ ស៊ុនដេត ដែលជាសាស្ត្រាចារ្យដឹកនាំ នូវសារណាបញ្ចប់ការសិក្សានេះ។ លោកសាស្ត្រាចារ្យតែងតែផ្តល់នូវ យោបល់ល្អៗ ដល់ពួកយើងក្នុងការស្រាវជ្រាវបន្ថែម និង កែតម្រូវនូវចំនុចខ្វះខាតទាំងអំបាលមានដែលកើតមានឡើង។ លោកគ្រូតែងផ្តល់នូវគំនិតថ្មីៗល្អៗដែលជាដើមទុនសម្រាប់យើងខ្ញុំទាំងពីរទៅថ្ងៃអនាគត។

លោក/លោកស្រី សាកលវិទ្យាធិការ សាកលវិទ្យាធិការរង គណៈគ្រប់គ្រងការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងលោកគ្រូ អ្នកគ្រូទាំងអស់ ដែលបានបង្ហាត់បង្រៀន ផ្តល់ចំណេះដឹង និង ដំបូន្មានល្អៗ ក្នុងការជួយឲ្យការស្រាវជ្រាវរបស់ខ្ញុំប្រកបដោយជោគជ័យ។

លោក/លោកស្រី ជានាយកនៃក្រសួងទេសចរណ៍ បុគ្គលិកទាំងអស់ និង អ្នកគ្រូលោកគ្រូនៃបណ្ណាល័យរបស់ក្រសួងទេសចរណ៍ ដែលផ្តល់ឱកាសដល់យើងខ្ញុំក្នុងការស្រាវជ្រាវឯកសារនានាដែលពាក់ព័ន្ធ។

ជាចុងក្រោយ ពួកយើងខ្ញុំជូនពរអ្នកមានគុណទាំងពីរ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យទាំងអស់នៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ និង ជាពិសេសលោកសាស្ត្រាចារ្យបណ្ឌិត ង៉ាន់ ស៊ុនដេត ឲ្យជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន សុភមង្គល ក្នុងក្រុមគ្រួសារ និង ទទួលបានជោគជ័យគ្រប់ភារៈកិច្ចទាំងអស់។

# អារម្ភកថា

យើងខ្ញុំជានិស្សិតឆ្នាំទី ៤ ផ្នែកសេដ្ឋកិច្ចអភិវឌ្ឍន៍ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច។ ក្នុងឆ្នាំ ២០១៧នេះជាឆ្នាំបញ្ចប់កាសិក្សារបស់យើង ដោយយើងខ្ញុំត្រូវធ្វើការ សរសេរសារណាបញ្ចប់ការសិក្សា។ ក្រោមការណែនាំរបស់លោកសាស្ត្រាចារ្យបណ្ឌិត ង៉ាន់ ស៊ុនដេត យើងខ្ញុំបានធ្វើការជ្រើសរើសយកប្រធានបទ ការចូលរួមរបស់វិស័យទេសចរណ៍ទៅក្នុងកំណើន សេដ្ឋកិច្ចជាតិ។

មូលហេតុដែលក្រុមយើងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទនេះឡើង ព្រោះយើងឃើញ ថាវិស័យទេសចរណ៍ ជាវិស័យមួយយ៉ាងសំខាន់ក្នុងការជម្រុញឲ្យមានកំណើនសេដ្ឋកិច្ចក្នុងពេល បច្ចុប្បន្ន និង ទៅអនាគត។ ហើយយើងនឹងធ្វើការវិភាគថាតើវិស័យទេសចរណ៍បានចូលរួមក្នុង កំណើនសេដ្ឋកិច្ចយ៉ាងដូចម្តេចខ្លះ?

ទន្ទឹមនឹងនោះដែរ យើងខ្ញុំសង្ឃឹមថាសៀវភៅសារណាបញ្ចប់ការសិក្សារបស់ក្រុមយើងខ្ញុំ អាចជួយប្អូនៗ ជំនាន់ក្រោយទុកជាឯកសារ និង ជាពិសេសសម្រាប់ប្អូននិស្សិតណាដែលចង់ធ្វើការ ស្រាវជ្រាវលើប្រធានបទ ដែលទាក់ទងនឹងវិស័យទេសចរណ៍ និង កំណើនសេដ្ឋកិច្ច ទុកជាទុនក្នុង ការស្រាវជ្រាវរបស់ប្អូនផងដែរ។

ជាចុងក្រោយ អាស្រ័យដោយការយល់ដឹងនៅមានកម្រិត ការខ្វះខាតបទពិសោធន៍ក្នុងការ អនុវត្តជាក់ស្តែង រួមនឹងឯកសារក៏ពុំសូវសម្បូរ យើងខ្ញុំជឿជាក់ថាប្រាកដជាមានកំហុសឆ្គង និង ចំណុចខ្វះខាតជាក់ជាមិនខាន។ ដូចនេះយើងខ្ញុំរីករាយ ស្វាគមន៍រាល់មតិរិះគន់ដើម្បីស្ថាបនាពី សំណាក់លោកគ្រូ អ្នកគ្រូ លោក លោកស្រី និង មិត្តសិស្សនិស្សិត ដើម្បីឲ្យសៀវភៅសារណាបញ្ចប់ ការសិក្សានេះកាន់តែល្អប្រសើរឡើង។

# មាតិកា

បញ្ជីតារាង ........ iii
បញ្ជីក្រាហ្វិក ........ iv
បញ្ជីឧបសម្ព័ន្ធ ........ v

## សេចក្តីផ្តើម

១. លំនាំបញ្ហា និង ចំនូលបញ្ហា ........ ០១
២. ចំណោទបញ្ហា ........ ០១
៣. គោលបំណងនៃការស្រាវជ្រាវ ........ ០២
៤.សារៈសំខាន់នៃការស្រាវជ្រាវ ........ ០២
៥.ដែនកំណត់នៃការស្រាវជ្រាវ ........ ០២
៦.វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ០២
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ០៣

## ជំពូកទី ១ រំលឹកទ្រឹស្តីកំណើនសេដ្ឋកិច្ច

១.១. និយមន័យកំណើនសេដ្ឋកិច្ច ........ ០៤
១.២. ទស្សនៈរបស់សេដ្ឋវិទូចំពោះកំណើនសេដ្ឋកិច្ចតាមរយៈវិស័យទេសចរណ៍ ........ ០៦
១.៣.រំលឹកទ្រឹស្តីទេសចរណ៍ ........ ០៧
១.៣.១. ទ្រឹស្តីមូលដ្ឋាននៃទេសចរណ៍ ........ ០៧
១.៣.២. ប្រភេទទេសចរណ៍ ........ ១០
១.៤. ការចូលរួមនៃវិស័យទេសចរណ៍ក្នុងកំណើនសេដ្ឋកិច្ចបរទេស ........ ១២
១.៤.១. ករណីប្រទេសថៃ ........ ១២
១.៤.២. ករណីប្រទេសសិង្ហបុរី ........ ១៤
១.៣.៣. ករណីប្រទេសចិន ........ ១៥
១.៣.៤. ករណីប្រទេសឡាវ ........ ១៦
១.៣.៥. ករណីប្រទេសភីលីពីន ........ ១៧

## ជំពូកទី២ សេដ្ឋកិច្ចកម្ពុជា និង វិស័យទេសចរណ៍

២.១.ស្ថានភាពសេដ្ឋកិច្ចកម្ពុជា ........ ២០
២.១.១. វិស័យកសិកម្មក្នុងប្រទេសកម្ពុជា ........ ២១

២.១.២. វិស័យឧស្សាហកម្ម........................................................ ២២
២.១.៣. វិស័យពាណិជ្ជកម្ម........................................................២៣
២.១.៤. វិស័យសំណង់........................................................២៣
២.១.៥. វិស័យសេវាកម្ម ........................................................២៤
២.២. ប្រវត្តិនៃការកើតឡើងនូវការធ្វើដំណើរទេសចរណ៍ ........................................................២៧
២.៣. ស្ថានភាពទេសចរណ៍ក្នុងប្រទេសកម្ពុជា ........................................................២៩
២.៤.ស្ថិតិទេសចរណ៍កម្ពុជា ........................................................ ៣០
២.៤.១. ស្ថិតិទេសចរណ៍ Inbound និង Outbound........................................................ ៣០

**ជំពូកទី ៣ ការវិភាគពីទំនាក់ទំនងនៃវិស័យទេសចរណ៍ និង កំណើនសេដ្ឋកិច្ច**

៣.១. កំណើនផលិតផលក្នុងស្រុកសរុប........................................................ ៣៦
៣.២. កំណើននៃទេសចរ ........................................................៣៧
៣.៣. ទំនាក់ទំនងនៃវិស័យទេសចរណ៍ក្នុងសេដ្ឋកិច្ចជាតិ ........................................................ ៣៨

**សេចក្តីសន្និដ្ឋាន និង អនុសាសន៍**

១. សេចក្តីសន្និដ្ឋាន........................................................៤០
២. អនុសាសន៍ ........................................................៤១

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

តារាង១.១. ចំនួនភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសថៃ ............ ១៣
តារាង១.២. ចំនួនភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសសិង្ហបុរី ............ ១៥
តារាង ១.៣. ចំនួនភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសឡាវ ............ ១៧
តារាង ១.៤. ចំនួនភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសភីលីពីន ............ ១៨
តារាង ២.១. កំណើនផសស និង កំណើនវិស័យនានា ............ ២៦
តារាង២.២. ចំនួនភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសកម្ពុជាពីឆ្នាំ២០១១ដល់២០១៦ ............ ៣១
តារាង ២.៣. មធ្យោបាយធ្វើដំណើរក្នុងការចូលមកកាន់ប្រទេសកម្ពុជា ............ ៣៤
តារាងទី២.៤. Outbound Tourist ............ ៣៥

# បញ្ជីក្រាហ្វិក

ក្រាហ្វិក ១.១. អត្រានៃវិស័យទេសចរណ៍ក្នុងសេដ្ឋកិច្ចថៃ.......................................................១៣
ក្រាហ្វិក ១.២. អត្រានៃវិស័យទេសចរណ៍ក្នុងសេដ្ឋកិច្ចសិង្ហបុរី..................................................១៤
ក្រាហ្វិក ១.៣. អត្រានៃវិស័យទេសចរណ៍ក្នុងសេដ្ឋកិច្ចចិន ......................................................១៦
ក្រាហ្វិក ១.៤. អត្រានៃទេសចរណ៍ក្នុងសេដ្ឋកិច្ចឡាវ ..............................................................១៦
ក្រាហ្វិក ១.៥. អត្រានៃទេសចរណ៍ក្នុងសេដ្ឋកិច្ចភីលីពីន..........................................................១៨
ក្រាហ្វិក ២.១. កំណើនវិស័យកសិកម្មក្នុងប្រទេសកម្ពុជា.........................................................២១
ក្រាហ្វិក ២.២. កំណើនវិស័យឧស្សាហកម្មក្នុងប្រទេសកម្ពុជា................................................. ២២
ក្រាហ្វិក ២.៣. កំណើនវិស័យពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា.................................................២៣
ក្រាហ្វិក ២.៤. កំណើនវិស័យសំណង់ក្នុងប្រទេសកម្ពុជា.........................................................២៣
ក្រាហ្វិក ២.៥. វិស័យទេសចរណ៍............................................................................................២៤
ក្រាហ្វិក ២.៦. កំណើនវិស័យដឹកជញ្ជូន និង ទូរគមនាគមន៍ .....................................................២៥
ក្រាហ្វិក ២.៧. កំណើនវិស័យអចលទ្រព្យក្នុងប្រទេសកម្ពុជា...................................................២៥
ក្រាហ្វិក ២.៨. កំណើនវស៏យលក់ដុំ និង លក់រាយ ..................................................................២៦
ក្រាហ្វិក ២.៩. បង្ហាញពីចំនួននៃភ្ញៀវទេសចរពីឆ្នាំ ២០១១ដល់២០១៦ចាប់ពីខែមករាដល់ធ្នូ......៣២
ក្រាហ្វិក ២.១០. ដប់ប្រទេសមានភ្ញៀវទេសចរចូលមកកាន់ប្រទេសកម្ពុជាច្រើនជាងគេឆ្នាំ២០១៦....
........................................................................................................................................ ៣៣
ក្រាហ្វិក ២.១១. ភាគរយនៃភ្ញៀវទេសចរក្នុងឆ្នាំ ២០១៦ ......................................................... ៣៤
ក្រាហ្វិក ៣.១. បង្ហាញអំពីកំណើននៃផលិតផលក្នុងស្រុកសរុប................................................ ៣៦
ក្រាហ្វិក ៣.២. បង្ហាញពីកំណើននៃទេសចរ..........................................................................៣៧
ក្រាហ្វិក ៣.៣.ក្រាបបង្ហាញពីទំនាក់ទំនងនៃកំណើនទេសចរ និងកំណើនសេដ្ឋកិច្ច ................. ៣៨

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី១៖ តារាង ANOVA

ឧបសម្ព័ន្ធទី២៖ Tourism Statistic Report Year 2016

ឧបសម្ព័ន្ធទី៣៖ ក្រាបកំណើនសេដ្ឋកិច្ចកម្ពុជា

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហា និង ចំនួលបញ្ហា

ប្រទេសកម្ពុជាត្រូវបានគេស្គាល់ថា ជាប្រទេសដែលកំពុងអភិវឌ្ឍន៍មួយក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប៉ុន្តែដំណើរការសេដ្ឋកិច្ចវិញហាក់បីមានភាពល្អប្រសើរ ក៏ព្រោះថាសេដ្ឋកិច្ចប្រទេសយើងនេះបានពឹងផ្អែក ទៅលើវិស័យសំខាន់ៗដូចជា វិស័យវាយនភណ្ឌ និង កាត់ដេរ វិស័យសំណង់ វិស័យកសិកម្ម ព្រមទាំងវិស័យទេសចរណ៍ជាដើម ដែលបានជួយជម្រុញដល់កំណើនសេដ្ឋកិច្ចពីមួយឆ្នាំទៅមួយឆ្នាំ។ ហើយយើងសង្កេតឃើញថាវិស័យទេសចរណ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការជម្រុញឲ្យមានកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ។

ជាការពិតណាស់ ប្រទេសកម្ពុជាជាប្រទេសមួយដែលសំបូរទៅដោយធនធានធម្មជាតិ ព្រៃភ្នំ ឆ្នេរសមុទ្រ ទន្លេ បឹងបួរ ប្រាង្គប្រាសាទ សិលាចារឹក ដ៏មហស្ចារ្យ ដែលសុទ្ធសឹងតែជាទីកន្លែងទាក់ទាញភ្ញៀវទេសចរជាតិ និង អន្តរជាតិមកពីគ្រប់ទិសទី ឲ្យចូលខ្លួនមកទស្សនានូវទេសភាពដ៏ល្អឥតខ្ចោះនេះ។ ជាហេតុធ្វើឲ្យប្រទេសកម្ពុជាទទួលបានចំណូលពីវិស័យទេសចរណ៍កាន់តែច្រើនឡើងៗ និង ធ្វើឲ្យប្រទេសកម្ពុជាកាន់តែល្បីល្បាញថែមទៀត។

តំបន់ទេសចរណ៍ធំៗ ក្នុងប្រទេសបានស្រូបយក កម្លាំងពលកម្មក្នុងប្រទេសកម្ពុជាយ៉ាងច្រើនដើម្បីបម្រើរឲ្យវិស័យនេះ ហើយវិស័យនេះបានរកចំណូលជូនជាតិយ៉ាងច្រើនសន្ធឹកសន្ធាប់ទៅក្នុង ផលិតផលជាតិសរុប(GDP) ប្រចាំឆ្នាំ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាក់ស្តែងការរីកចម្រើននៃវិស័យទេសចរណ៍ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជា។ ភាពប្រសើរឡើងនូវវិស័យទេសចរណ៍ គឺជាមុខព្រួយមួយក្នុងការទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត។ បើកាលណាមានទេសចរអន្តរជាតិចូលមកកាន់ប្រទេសកម្ពុជាកាន់តែច្រើននោះតម្រូវការដូចជា សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន អាហារដ្ឋាន រមណីយដ្ឋានធម្មជាតិ និង កែច្នៃនានា កាន់តែខ្ពស់ឡើងៗ ដែលជាផ្នែកមួយជម្រុញដល់កំណើនសេដ្ឋកិច្ច។ ចង់ដឹងថាតើ "វិស័យទេសចរណ៍បានចូលរួម ក្នុងកំណើនសេដ្ឋកិច្ច " យ៉ាងណា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទ " ការចូលរួមរបស់វិស័យទេសចរណ៍ក្នុងកំណើនសេដ្ឋកិច្ចជាតិ" មានគោលបំណងសំខាន់ៗដូចតទៅ៖

ស្វែងយល់ពីការរួមចំណែកនៃវិស័យទេសចរណ៍ក្នុងកំណើនសេដ្ឋកិច្ច របស់ប្រទេសកម្ពុជាក្នុងពេលបច្ចុប្បន្ន។

បង្ហាញអំពីទិន្នន័យនានានៃវិស័យទេសចរណ៍

## ៤.សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃការស្រាវជ្រាវប្រធានបទខាងលើ គឺចង់បង្ហាញដល់មិត្តអ្នកអានគ្រប់គ្នាពីៈ

សារៈសំខាន់នៃវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា

ផ្តល់នូវជាលទ្ធផលស្រាវជ្រាវថ្មីៗ ទុកសម្រាប់អ្នកស្រាវជ្រាវបន្ត

## ៥.ដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺផ្តោតទៅលើការចូលរួមរបស់វិស័យទេសចរណ៍ នៅក្នុងប្រទេសកម្ពុជាថាតើវិស័យនេះបានចូលរួមដល់កំណើនសេដ្ឋកិច្ច យ៉ាងដូចម្តេចខ្លះ។ លើសពីនេះទៅទៀតការស្រាវជ្រាវមួយនេះ បានកំណត់យកទិន្នន័យនៃទេសចរអន្តរជាតិចាប់ពីឆ្នាំ ២០១១មកត្រឹមឆ្នាំ ២០១៦ ព្រមទាំងលើកឡើងពីកំណើនសេដ្ឋកិច្ច និង កំណើនភ្ញៀវទេសចរ មកធ្វើការវិភាគដើម្បីសសេរជាសមីការទំនាក់ទំនងផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការស្រាវជ្រាវ យើងបានជ្រើសរើស វិធីសាស្ត្របែបបរិមាណ (Quantitative Method)។

**តម្រូវការទិន្នន័យៈ** ទិន្នន័យសម្រាប់ធ្វើការវិភាគ យើងបានប្រើប្រាស់ទិន្នន័យទី២ (Secondary data).

**កន្លែងពាក់ព័ន្ធ**: ១. ក្រសួងទេសចរណ៍: ដោយបានចុះស្រាវជ្រាវឯកសារនៅបណ្ណាល័យតូចនៃក្រសួងទេសចរណ៍ ព្រមទាំងទទួលបានទិន្នន័យទាំងនេះមកពី នាយកដ្ឋានស្ថិតិទេសចរណ៍។

២. ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ: ទទួលបានទិន្នន័យពីអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ។

**ការវិភាគទិន្នន័យៈ** ចំពោះការវិភាគទិន្នន័យយើងបានបញ្ចូលទិន្នន័យកំណើន GDP និងកំណើននៃភ្ញៀវទេសចរទៅក្នុងកម្មវិធី Excel រួចយើងបានទទួលនូវតារាង ANOVA។

**លទ្ធផលនៃការស្រាវជ្រាវៈ** តាមតារាង ANOVA យើងទទួលរូបមន្តទំនាក់ទំនងដូចខាងក្រោមៈ

$$GDP = \beta_0 + \beta_1(Tourism) + U_i \, , i = 1,2,3 \ldots \ldots \ldots \ldots n$$

GDP= វាស់ជាភាគរយ

Tourism=វាស់ជាភាគរយ

$U_i$= អថេរដទៃទៀតដែលមានឥទ្ធិពលលើកំណើនសេដ្ឋកិច្ច (error term)

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងខ្លឹមសារទាំងមូលនៃស្នាដៃសារណានេះ យើងបានបែងចែកជាបីជំពូក។

ជំពូកទី១៖ ការរំលឹកទ្រឹស្តីដែលពាក់ព័ន្ធនានា ទៅនឹងវិស័យទេសចរណ៍ និង កំណើនសេដ្ឋកិច្ច។ លើសពីនេះយើងថែមទាំងលើកយកពីការចូលរួមនៃវិស័យទេសសចរណ៍របស់ប្រទេសចំនួន៥មកធ្វើការបង្ហាញមានដូចជា៖ ថៃ សង្ហបុរី ចិន ឡាវ និង ភីលីពីន ផងដែរ។

ជំពូកទី២៖ ក្នុងជំពូកនេះ យើងនឹងធ្វើការបង្ហាញពីដំណើរការនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ប្រវត្តិខ្លះៗនៃការកកើតឡើងនូវការធ្វើដំណើរទេសចរណ៍។ ជាពិសេសគឺទិន្នន័យនានានៃវិស័យទេសចរណ៍ផ្ទាល់តែម្តង។

ជំពូកទី៣៖ យើងនឹងគូរក្រាបដែលបង្ហាញពីកំណើនសេដ្ឋកិច្ច និង កំណើននៃទេសចរ ព្រមទាំង សសេរសមីការ ទំនាក់ទំនងរបស់កំណើនសេដ្ឋកិច្ច និង ទេសចរ។ ចុងក្រោយយើងនឹងធ្វើសេចក្តីសន្និដ្ឋាន និង ផ្តល់ជាអនុសាសន៍ខ្លះអំពីខ្លឹមសារនៃសារណាទាំងមូល។

# ជំពូកទី១

# រំលឹកទ្រឹស្តីកំណើនសេដ្ឋកិច្ច

# ជំពូកទី១៖ រំលឹកទ្រឹស្តីកំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចពិតជាមានសារៈសំខាន់ក្នុងការ អភិវឌ្ឍន៍ប្រទេសជាតិនីមួយៗដូចនេះ ហើយក្នុងជំពូកនេះយើងនឹងសិក្សាអំពីនិយមន័យ និង ទ្រឹស្តីរបស់កំណើនសេដ្ឋកិច្ច ព្រមទាំងសិក្សាថាតើវិស័យអ្វីខ្លះដែលនឹងជួយជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច។

## ១.១. និយមន័យកំណើនសេដ្ឋកិច្ច

កំណើនសេដ្ឋកិច្ចគឺជា ការកើនឡើងនូវសមត្ថភាពផលិតទំនិញ និង សេវាកម្មក្នុងណាឆ្នាំមួយទៅនឹងឆ្នាំមុន។ ហើយគេអាចវាស់កំណើនសេដ្ឋកិច្ចតាមរយៈ GDP ( gross domestic product) និង GNP (gross national product)។[1] យើងនឹងសិក្សាអំពី ទ្រឹស្តីកំណើនសេដ្ឋកិច្ចដូចជា៖ ទ្រឹស្តីក្លាសិក(Classical Theory) ទ្រឹស្តីណេអូក្លាស៊ិក( Neo-classical Theory) និងទ្រឹស្តីរបស់សេដ្ឋវិទូនានា។

ជាដំបូងយើងសិក្សាពី កំណើនសេដ្ឋកិច្ច តាមរយៈទស្សនៈក្លាស៊ីក(Classical Theory) ដែលត្រូវបានចូលរួមដោយសេដ្ឋកិច្ចវិទូដូចជា លោក Adam Smith លោក David Ricardo លោក Thomas Malthus។[2]

លោកAdam Smith ត្រូវបានចាត់ទុកជាសេដ្ឋវិទូក្លាស៊ីកដ៏ល្បីល្បាញមួយរូបដែលបានសរសេរអត្ថបទមួយនៅក្នុងឆ្នាំ 1776 មានចំណងជើងថា "The Wealth of Nation" ដែលគោលបំណងរបស់អត្ថបទនេះគឺបង្ហាញពីភាពមានបានរបស់ប្រទេស។[3] លោកបានយល់ឃើញថា កំណើនកើតមានឡើង អាស្រ័យទៅតាមជំនាញ និង ដំណើរការផលិតកម្ម និងការចូលរួមបញ្ចូលមូលធនក្នុងដំណើរការទាំងនោះ(Donald.J, n.d)។ ចំណែកឯរដ្ឋាភិបាលវិញ គឺគួរតែប្រកាន់ឥរិយាបថមួយ ដែលអនុញ្ញាតទីផ្សារមានដំណើរការផលិតកម្មទំនិញ និង សេវា ព្រមទាំងបែងចែកផលិតផលទាំងនោះក្នុងទីផ្សារដោយខ្លួនឯង ព្រោះដំណើរការបែបនេះផ្តល់នូវសេរីភាពពេញលេញដល់ដំណើរការសកម្មភាព ដែលជម្រុញចលនាសេដ្ឋកិច្ចក្នុងប្រទេស។[4] រីឯទស្សនៈរបស់លោកDavid Ricardo ជា

ទស្សនៈដែលស្ថិតក្នុងសម័យកាលបដិវត្តន៍ ឧស្សាហកម្មដោយនៅក្នុងឆ្នាំ ១៨១៧ បានបោះផ្សាយសៀវភៅដែលនិយាយអំពី "ទ្រឹស្តីមូលដ្ឋាននៃគោលននយោបាយសេដ្ឋកិច្ច និង ពន្ធ"។[5] នៅក្នុងដំណើរការធ្វើឲ្យសេដ្ឋកិច្ចមានភាពលូតលាស់ លោកបានបង្ហាញពីកត្តាមួយចំនួនដែលអាច

---

[1] www.investopedia.com/terms/e/economicgrowth.asp
[2] (http://www.investopedia.com /term/c/classicaleconomics.asp)
[3] សាស្ត្រាចារ្យ ម៉ម ចរិយាវុធ និង សាស្ត្រាចារ្យ ងួន ហេង, "សេដ្ឋកិច្ចនយោបាយ" ,បោះពុម្ពលើកទី៣,ឆ្នាំ២០១២,ទំព័រ ១១៣-១១៤
[4] ( What are the different theory of economics growth?, n.d)
[5] http://www.wisegeek.com/what-are-the-different-theorist-of-economic-growth.htm), n.d)

សម្រួលដល់កំណើន ហើយកត្តាទាំងនោះមានដូចជាសារៈសំខាន់ នៃវិស័យកសិកម្ម, តម្លៃនៃពលកម្ម, ការបែងចែកចំណូលជាតិដែលបានមកពីម្ចាស់ដី, ពួកមូលធន និង កម្មករ, និងទ្រឹស្តីឧត្តមប្រយោជន៍ប្រៀបធៀបជាដើម។ យោងតាមកត្តាចម្បងទាំងនោះ គេសង្កេតឃើញថា ទ្រឹស្តីឧត្តមប្រយោជន៍ប្រៀបធៀប ជាទស្សនៈចម្បងដែលលោក David Ricardo ប្រើជាគោលក្នុងការពន្យល់ ពីដំណើរការដែលជម្រុញដល់កំណើនសេដ្ឋកិច្ច។[6] ទ្រឹស្តីនេះបង្ហាញពីសមត្ថភាពនៅក្នុងការផលិតទំនិញអ្វីមួយ ត្រង់តម្លៃទាបជាងទំនិញរបស់ប្រទេសដទៃ ដែលតម្លៃទាបនេះ ធ្វើឲ្យប្រទេសដែលជាអ្នកផលិតអាចធ្វើការប្រកួតប្រជែង យ៉ាងមានប្រសិទ្ធិភាព នៅក្នុងទីផ្សារ និង មានលទ្ធភាពបង្កើនការងារបន្ថែមនៅក្នុងស្រុក។ មិនតែប៉ុណ្ណោះ លោក Thomas Malthus ក៏ជាបុគ្គលមួយរូបដែលពន្យល់ពីដំណើរការនៃកំណើនសេដ្ឋកិច្ច របស់ប្រទេសមួយ ដោយលោកចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើកំណើនប្រជាជន។[7] លោកបានបង្ហាញថា កំណើនសេដ្ឋកិច្ចកើនឡើងស្របពេលដែលមូលធនសរុបក្នុងប្រទេសមានការកើនឡើង ហើយមូលធនក្នុងប្រទេសនេះកើនឡើងអាស្រ័យទៅលើបរិមាណផលិត។ ប្រសិទ្ធិភាពនៃការផលិតទំនិញ និង សេវាទាំងនៅក្នុងវិស័យកសិកម្ម និងឧស្សាហកម្មមានការកើនឡើង នៅពេលដែល ដី ពលកម្ម មូលធន ត្រូវបានរៀបចំ និង ប្រើប្រាស់យ៉ាងត្រឹមត្រូវ។ ទន្ទឹមនឹងការកើនឡើង នៃមូលធនតាមរយៈកំណើននៃបរិមាណផលិត ដែលធ្វើឲ្យមានកំណើនសេដ្ឋកិច្ច វាក៏អាស្រ័យទៅលើផ្នែកក្រៅសេដ្ឋកិច្ចមួយចំនួនដែរ ដូចជា: ស្ថេរភាពនយោបាយ និង បុគ្គលម្នាក់ៗ ក្នុងប្រទេសនោះផងដែរ។[8]

លើសពីនេះទៅទៀតទ្រឹស្តីណេអូក្លាស៊ីកទៅលើកំណើនសេដ្ឋកិច្ច ជាទ្រឹស្តីសេដ្ឋកិច្ចមួយដែលត្រូវបានបង្កើតឡើងដោយលោក Robert Solow នៅសតវត្សន៍ទី២០ កំឡុងឆ្នាំ១៩៥០ ដល់ ១៩៦៩។ ជាដំបូងលោក Robert Solow បានធ្វើការអភិវឌ្ឍន៍ទស្សនៈក្លាស៊ីក ដោយលោកបានបន្ថែមថាការសន្សំជាកត្តាមួយផ្សេងទៀតដែលជួយជម្រុញទៅដល់កំណើនសេដ្ឋកិច្ច ហើយស្របពេលជាមួយគ្នានេះកំណើននៃការសន្សំ និង មានការកើនឡើងក្នុងស្ថានភាព ដែលការចំណាយមានការកាត់បន្ថយ ( What are the different economic theory, n.d)។ ក្រៅពីផ្តល់ទស្សនៈបន្ថែមទៅលើទស្សនៈក្លាស៊ីក លោក Robert Solow រួមគ្នាជាមួយនិងលោក Paul Romer និង លោក Paul Omerodបានបង្កើតនូវទ្រឹស្តីកំណើនសេដ្ឋកិច្ចថ្មីមួយដែលមានឈ្មោះថា ទ្រឹស្តីណេអូក្លាស៊ីក ដោយ

[6] (economics Growth part III, 2016)

[7] (the concise Encyclopedia of Economics, 2008)

[8] (Lauren, F,n.d)

ទ្រឹស្តីនេះក៏បានបន្ថែមទៅលើទស្សនៈ Adam Smith ផងដែរ។[9] ទ្រឹស្តីនេះបង្ហាញថា ការកើនឡើងនៃកម្លាំងពលកម្ម ជាកត្តាមួយចម្បងក្នុងកំណើនសេដ្ឋកិច្ច ហើយជាពិសេសទៅទៀតនោះ កំណើនសេដកិច្ចនិងរឹតតែបន្តកើនឡើង នៅពេលដែលគុណភាពនៃកម្លាំងពលកម្មតាមរយៈការអប់រំ និងការហ្វឹកហាត់ ការកើនឡើងនៃសហាគ្រិនភាពថ្មីៗ និង កំណើននៃការវិនិយោគកើនឡើង។ ទ្រឹស្តីនេះក៏បង្ហាញពីស្ថេរភាព នៃកំណើនសេដ្ឋកិច្ច ដោយមានការចូលរួម ពីកត្តាជម្រុញបី គឺ កម្លាំងពលកម្ម មូលធន និងបច្ចេកវិទ្យា ( Phil, M.n.d)។ លំនឹងនៃកំណើនសេដ្ឋកិច្ច កើតមានឡើងជាបណ្តោះអាសន្ន នៅពេលដែលទំហំនៃកម្លាំងពលកម្ម មូលធន និង កម្រិត នៃបច្ចេកវិទ្យាត្រូវបានកែតម្រូវយ៉ាងសមស្រប ហើយកំណើនសេដ្ឋកិច្ច និងបន្តកើនឡើង ពេលដែលមានការរីកចម្រើន ផ្នែកបច្ចេកវិទ្យា (International Economics, n.d)។

ចំណែកឯទ្រឹស្តីលោកSchumpeterian ជាទ្រឹស្តីបង្ហាញពីកំណើនសេដ្ឋកិច្ចមួយដែលត្រូវបានបង្កើតឡើងដោយសេដ្ឋវិទូ ជនជាតិអូស្ត្រាលីម្នាក់ឈ្មោះថា Joseph Schumpeter ក្នុងទសវត្សន៍ទី២០ (as cited from Hash, D.2016)។ ក្នុងទ្រឹស្តីនេះ លោកបានធ្វើការអង្កេតមួយជំហានបន្ថែមទៀតពីលើឥទ្ធិពលនៃបច្ចេកវិទ្យា និង ការបង្កើតថ្មីដែលចូលរួមក្នុងកំណើនសេដ្ឋកិច្ច ដែលទស្សនៈរបស់លោកបានកំណត់ថា ស្របពេលដែលបច្ចេកវិទ្យា មានការរីកចម្រើនលូតលាស់ ការបង្កើតគំនិតច្នៃប្រឌិតនិងការផលិតទំនិញនិង សេវាថ្មីៗ ដោយរួមប្រើប្រាស់ផលប្រយោជន៍ ដែលបានមកពីការរីកចម្រើនខាងបច្ចេកវិទ្យាទៀតនោះ អាចជួយឲ្យមានកំណើនសេដ្ឋកិច្ចយ៉ាងរហ័ស (Economic Growth part III, 2015)។

## ១.២. ទស្សនៈរបស់សេដ្ឋវិទូចំពោះកំណើនសេដ្ឋកិច្ចតាមរយៈវិស័យទេសចរណ៍

វិស័យទេសចរណ៍បានក្លាយទៅជាវិស័យសេវាកម្មដែលមានសារៈសំខាន់ នៅលើពិភពលោកដោយគេចាត់ទុកវាថាជាកម្លាំងជម្រុញឲ្យមានកំណើនសេដ្ឋកិច្ច។ ទោះបីជាវិស័យនេះពុំមែនជាអ្នកផលិតនូវផលិតផលអ្វី ប៉ុន្តែវិស័យនេះគឺជាអ្នកប្រើប្រាស់នូវផលិតដែលបានមកពីវិស័យ ផ្សេងៗទៀតមានន័យថាវាបានជម្រុញឲ្យវិស័យផ្សេងៗទៀតរីកចម្រើនឡើង តាមរយៈតម្រូវការរបស់វា។

យើងដឹងហើយថា ក្នុងប្រទេសកម្ពុជាមានកន្លែងដែលស្រស់ស្អាតជាច្រើន ដែលទាក់ទាញភ្ញៀវទេសចរណ៍ឲ្យចូលមកកាន់ប្រទេសកម្ពុជាយើង ដូចនេះហើយយើងអាចនឹងរកប្រាក់ចំណូលបានពីវិស័យទេសចរណ៍នេះតាមរយៈការលក់សំបុត្រចូលទស្សនាតំបន់ទេសចរណ៍នានាក្នុងប្រទេ

[9] http://www.wisegeek.com/what-are-the-different-theories-of-economic-growth.htm)

ស។ ម៉្យាងវិញទៀតកាលណាមានភ្ញៀវទេសចរ ច្រើនចូលមកកាន់ប្រទេស នោះនឹងធ្វើឲ្យមានតម្រូវការ នូវទំនិញ និង សេវា កើនឡើង។ ហើយបើកាលណាតម្រូវការទំនិញ( អាហារ,សំភារៈប្រើប្រាស់.......) និង សេវា( សេវាកម្មធ្វើដំណើរ, កន្លែងស្នាក់នៅ.............)កើនឡើងនោះនឹងធ្វើឲ្យមានកំណើនសេដ្ឋកិច្ច។ មិនតែប៉ុណ្ណោះវិស័យទេសចរណ៍ថែមទាំងអាចបង្កើត និង បង្កើនការងារដល់ប្រជាជនក្នុងប្រទេស ដែលជាហេតុធ្វើឲ្យកម្លាំងពលកម្មកើនឡើង នោះនឹងធ្វើឲ្យបរិមាណផលិតកម្មកើនឡើងដែរ ហើយនេះគឺជាកត្តាមួយទៀតក្នុងការធ្វើឲ្យមានកំណើនសេដ្ឋកិច្ច ដូចជាទស្សនៈសេដ្ឋកិច្ចរបស់លោកសេដ្ឋវិទូ Thomas Malthus បាននិយាយថា "កំណើនសេដ្ឋកិច្ចកើនឡើង ស្របពេលដែលមូលធនសរុបក្នុងប្រទេសមានការកើនឡើង ហើយមូលធនកើនឡើងក្នុងប្រទេសអាស្រ័យនឹងបរិមាណផលិតកើនឡើង។"

សរុបមកតាមវិស័យទេសចរណ៍បានផ្តល់នូវឥទ្ធិពលវិជ្ជមានសំខាន់ៗក្នុងការជម្រុញកំណើនសេដ្ឋកិច្ចដូចជាៈ

→ បង្កើតការងារ

→ បែងចែកប្រាក់ចំណូលរបស់ជាតិ

→ បង្កើនសកម្មភាពវិនិយោគ

→ បង្កើនគុណភាពផលិតផល។

## ១. ៣.វិវត្តទ្រឹស្តីទេសចរណ៍

ទេសចរណ៍ក្លាយជាវិស័យសេវាកម្មមួយយ៉ាងធំក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច។ យើងសង្កេតឃើញថាការកើតមានទស្សនៈផ្សេងៗគ្នាជាច្រើនទៅលើនិយមន័យនៃពាក្យ ទេសចរណ៍។

### ១.៣.១. ទ្រឹស្តីមូលដ្ឋាននៃទេសចរណ៍

ទស្សនាវដ្តី សេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ត្រីមាសទី៤ ឆ្នាំ២០០០) បានឲ្យនិយមន័យទេសចរណ៍ថាជាឧស្សាហកម្មសេវាកម្មដ៏ធំបំផុតនៅក្នុងពិភពលោក ដែលមានតួនាទីដឹកនាំសេដ្ឋកិច្ចជាតិ ព្រមទាំងបានបង្កើននូវការងារធ្វើជាច្រើនដល់ប្រជាពលរដ្ឋ។ សូម្បីតែកិច្ចប្រជុំកំពូលអាស៊ាននៅថ្ងៃទី៤ និង៥ ខែវិច្ឆិកា ឆ្នាំ២០០២ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមាន១៥ប្រទេសបានផ្តោតការយកចិត្តទុកដាក់ទៅលើវិស័យទេសចរណ៍ ក្នុងតំបន់នៃប្រទេសនីមួយៗ។ ចំណែកឯរដ្ឋាភិបាលកម្ពុជា ក៏ចាត់ទុកវិស័យនេះជាវិស័យអាទិភាពមួយដែរ ព្រោះយើងយល់ឃើញថា "ការអភិវឌ្ឍន៍វិស័យទេសចរណ៍នៅក្នុងប្រទេសអាចបង្កើតជាគ្រឹះដ៏រឹងមាំមួយសម្រាប់បង្កើន ប្រាក់ចំណូលពិតប្រាកដដល់ប្រទេស និងប្រជាជន ដែលជះឥទ្ធិពលជាវិជ្ជមានទៅលើការខិតខំប្រឹងប្រែង ដើម្បីសម្រេចបាន

នូវការកាត់បន្ថយភាពក្រីក្រ" ដោយផ្អែកតាមទស្សនាវដ្ដី សេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ត្រីមាសទី៤ ឆ្នាំ ២០០០ ទំព័រ ១៩)។ ទន្ទឹមគ្នានេះដែរ យើងឃើញមានការកំណត់និយមន័យជាច្រើនស្ដីអំពីទេសចរណ៍ថាគឺជាសកម្មភាព របស់មនុស្សដែលធ្វើដំណើរ កំសាន្ត ជំនួញ និងគោលបំណងផ្សេងៗ ទៅកន្លែងនានា ដែលស្ថិតនៅខាងក្រៅបរិស្ថានរបស់ពួកគេរស់នៅធម្មតាសព្វថ្ងៃ ហើយស្នាក់នៅទីនោះមិនច្រើនជាងមួយឆ្នាំយោងតាម William F. Theobald (2002)។ ហើយបើយើងចង់បញ្ជាក់ពីអ្នកទេសចរវិញ គឺជាបុគ្គលណាមួយដែលធ្វើដំណើរចេញពីផ្ទះរបស់ពួកគេលើសពីរយៈពេល ២៤ម៉ោងជាមួយ គោលបំណងប្រើប្រាស់ពេលវេលា លំហែកាយរបស់ពួកគេសម្រាប់ កំសាន្ត សុខភាពសិក្សាសាសនា ឬកីឡាបកស្រាយដោយ បេងហុង សុជាតិ និងខេមរ៉ូ (២០០២, ទំព័រ៣៤)។

សរុបសេចក្ដីមកយើងឃើញថាទេសចរណ៍ ជាសកម្មភាពធ្វើដំណើរ និង ការស្នាក់នៅតំបន់ណាមួយរបស់ប្រជាពលរដ្ឋចាប់ពី ២៤ម៉ោងឡើងទៅ និងមិនលើសពីមួយឆ្នាំ ដើម្បីលំហែកំសាន្ត អាជីវកម្ម ទស្សនា។ល។ បើសិនជាមិនទាក់ទងការផ្លាស់ប្ដូរលំនៅ និងបំរើការងារដើម្បីទទួលប្រាក់កំរៃយោងតាម សួន រ៉ានី(២០០២, ទំព័រ៣៤)។ អាស្រ័យហេតុនេះយើងឈ្វេងយល់បានថាពលរដ្ឋគ្រប់រូបដែលគ្រាន់តែធ្វើដំណើរកំសាន្ត យកខ្យល់អាកាសទៅសួរសុខទុក្ខបងប្អូន ទៅទទួលទានអាហារនៅខាងក្រៅមិនអាចកំណត់ថាភ្ញៀវទេសចរបំរើឲ្យ វិស័យទេសចរណ៍នោះទេ ព្រោះការធ្វើដំណើររបស់ពួកគេមិនលើសពី២៤ម៉ោង។ សរុបមកពាក្យទេសចរណ៍ (Tourism) កើតឡើងនៅក្នុងភាសាអង់គ្លេសនៅដើមសតវត្សទី ១៩ ហើយឫសគល់នៃពាក្យនេះគឺ Tour មានន័យថាជាការធ្វើដំណើរកំសាន្ត។

និយមន័យទេសចរណ៍ត្រូវបានធ្វើឡើងតាមរយៈចរិតលក្ខណៈសេដ្ឋកិច្ចរបស់វា ដូចខាងក្រោម:

ជាលទ្ធផលនៃការធ្វើដំណើរទៅកាន់តំបន់ណាមួយផ្សេងពីកន្លែងរស់នៅ អចិន្ត្រៃយ៍

ស្នាក់នៅ និងស្ថិតនៅក្នុងតំបន់ដែលទៅដល់ លើសពី២៤ម៉ោង

ធ្វើសកម្មភាពជាមួយគោលបំណងទេសចរណ៍ស្របច្បាប់ដែលអនុញ្ញាត្តិ

វិលត្រលប់ទៅកន្លែងរស់នៅដើមវិញក្រោយបញ្ចប់សកម្មភាព

មិនធ្វើការងារដែលទទួលបាននូវប្រាក់កំរៃផ្ទាល់ខ្លួន(ចាយនិងបន្សល់ទុកប្រាកដក្នុងតំបន់)។

អង្គការសហប្រជាជាតិបានកំណត់និយមន័យឲ្យ ទេសចរណ៍ថាជាការធ្វើសកម្មភាពកំសាន្តដែលជះឥទ្ធិពលទៅលើការពង្រឹងសុខភាព ការរីកចំរើននិងការអភិវឌ្ឍន៍ កំលាំងកាយនិងចិត្តរបស់មនុស្ស ដែលធ្វើចលនា ឬធ្វើដំណើរចេញពីកន្លែងរស់នៅ ជាប្រចាំក្នុងរយៈពេលណាមួយ។

និយមន័យរបស់ទេសចរណ៍ ត្រូវបានកំណត់ទៅតាមលក្ខណៈពិសេសនៃសេដ្ឋកិច្ច នយោបាយ និងសង្គមរបស់វា។ នៅប្រទេសកម្ពុជា ក្រោយពីមានបំលាស់ប្តូរប្រព័ន្ធគ្រប់គ្រងនិងឈានទៅប្រកាន់យករបបសេដ្ឋកិច្ចទីផ្សារសេរីនៅឆ្នាំ១៩៨៩ ទេសចរណ៍បានក្លាយជាវិស័យឈានមុខមួយ។ វាក្លាយទៅជាអាជីវកម្ម ដែលបោះជំហានទៅមុខយ៉ាងលឿនបើធៀបនិងវិស័យផ្សេងៗទៀតរបស់សេដ្ឋកិច្ចជាតិ។

នៅបណ្តាប្រទេសមួយចំនួន ក្នុងច្បាប់ជាតិ និងបទប្បញ្ញត្តិផ្សេងៗ ដែលជានិតិវិធីសាវាចរកម្មវិធីនិយ័តកម្ម ដែលធ្វើឡើងសម្រាប់ជាកំណែទំរង់ទេសចរណ៍ ការកំណត់ និយមន័យទេសចរណ៍និងទេសចរត្រូវបានធ្វើឡើងដោយមានភាពខុសប្លែកពីគ្នា (មិនដូចគ្នាទាំងស្រុងទេ) ហើយការកំណត់ចំណាត់ថ្នាក់ និងវិភាគលើនិយមន័យនេះត្រូវបាន ទូទាត់ច្បាស់លាស់អំពីឥទ្ធិពលនយោបាយនិងបន្ទាប់មកសេដ្ឋកិច្ច។

ដោយខុសប្លែកពីការធ្វើដំណើរទេសចរណ៍ ជាការធ្វើដំណើរមួយរបស់មហាជន ក្នុងរយៈពេលដ៏ខ្លីមួយតែមិនតិចជាង ២៤ម៉ោង ហើយមិនលើសពីមួយឆ្នាំជាប់ៗគ្នា។ កត្តាទាំងនេះត្រូវបានធ្វើឡើងដោយផ្អែកលើទស្សនវិស័យពីរ ដូចខាងក្រោមៈ

ទេសចរ ចាំបាច់ស្ថិតនៅក្នុងប្រភេទអ្នកដែលបានមកដល់ ហើយមានការស្នាក់នៅនៅពេលយប់។ មានន័យថា ចាំបាច់ត្រូវរកទីកន្លែងសំណាក់។ មនុស្សមិនអាចឈរជើងបានក្នុងរយៈពេល ២៤ម៉ោងនោះទេ គេចាំបាច់ត្រូវសំរាកដែលតំរូវឲ្យជួល ឬទិញបន្ទប់សណ្ឋាគារ ផ្ទះសំណាក់ឬមូលដ្ឋានសេវាកម្មស្នាក់នៅដ៏ទៃ។ល។

ការធ្វើដំណើររយៈពេលយូរ ជានិច្ចកាលមានបុគ្គលតិចតួចតែប៉ុណ្ណោះ។ ការធ្វើដំណើរនេះអាចពន្យាពេលពីមួយ ឬច្រើនឆ្នាំសមស្របទៅតាមគោលបំណងនៃដំណើរ។ ជារៀងរាល់ឆ្នាំមានការរៀបចំធ្វើដំណើរប្រភេទនេះសម្រាប់គោលដៅផ្សេងៗ តែភាគច្រើនដើម្បីចងក្រងជាឯកសារការស្រាវជ្រាវវិទ្យាសាស្ត្រ។ល។ ឧទាហរណ៍ៈ ដើម្បីអ្វីដែល ចំណាយពេលជាច្រើនឆ្នាំក្នុងការធ្វើដំណើរតាមកង់ជុំវិញពិភពលោក ឬការធ្វើដំណើរផ្សងព្រេងតាមទូកជុំវិញមហាសមុទ្រ។ល។ ការធ្វើដំណើរទាំងនេះ គ្មានទំនាក់ទំនងបន្តិចណា ជាមួយទេសចរណ៍នោះទេ ព្រោះថាវាមានគោលដៅច្បាស់ដែលមិនសមស្រប និង គោលដៅរបស់ទេសចរណ៍ រីឯរយៈពេលធ្វើដំណើរក៏មានច្រើនលើសលុបពីការធ្វើ ដំណើរជាទេសចរណ៍ដែរ។

### ១.៣.២.ប្រភេទទេសចរណ៍

តាមការសិក្សាគេសង្កេតឃើញថា ទេសចរណ៍ត្រូវបាន បែងចែកជាច្រើនប្រភេទ ប៉ុន្តែនៅក្នុង ឯកសារនេះ យើងខ្ញុំសូមលើកយកតែពាក្យ ទេសចរណ៍ក្នុងស្រុក(Domestic Tourism) ទេសចរណ៍ជាតិ( National Tourism) ទេសចរណ៍អន្តរជាតិ( international Tourism) និង ទេសចរណ៍សង្គម ( Social Tourism) ដើម្បីយកមកបកស្រាយជានិយមន័យ។

**ទេសចរណ៍ក្នុងស្រុក**(Domestic Tourism) សំដៅលើសកម្មភាពទេសចរណ៍របស់ប្រជាពលរដ្ឋដែលធ្វើដំណើរកំសាន្ត នៅក្នុងប្រទេសរបស់ខ្លួន ពោលគឺមិនឆ្លងកាត់ព្រំដែន។[10]

**ទេសចរណ៍ក្នុងស្រុក**(Domestic Tourism) គឺជាបណ្តុំសកម្មភាពរបស់ប្រជាពលរដ្ឋក្នុងប្រទេសមួយធ្វើដំណើរកំសាន្ត នៅក្នុងទឹកដី ប្រទេសកំណើតរបស់ខ្លួន ប៉ុន្តែនៅក្រៅបរិយាកាសក្រៅពីប្រក្រតី(ផ្ទះ)របស់ពួកគេ។[11]

**ទេសចរណ៍ក្នុងស្រុក**(Domestic Tourism)សំគាល់លើការធ្វើដំណើរទស្សនាលំហែ របស់ប្រជាជននៃប្រទេសមួយក្នុងទឹកដីនៃប្រទេសរបស់ពួកគេផ្ទាល់។[12]

ជារួមទេសចរណ៍ក្នុងស្រុក មានអត្ថន័យថាជាសកម្មភាពធ្វើដំណើរទេសចរណ៍របស់មនុស្សនៃជាតិសាសណ៍មួយធ្វើដំណើរសំរាកទស្សនា លំហែ ក្នុងទឹកដីទីកំណើតរបស់ពួកគេផ្ទាល់ដោយមិនមានការឆ្លងហួសព្រំដែនទៅកាន់ប្រទេសក្រៅ។

**ទេសចរណ៍ជាតិ**( National Tourism)វិញក៏មានអ្នកស្រាវជ្រាវផ្នែកទេសចរណ៍និងប្រភពឯកសារជាច្រើន បានលើកយកមកពន្យល់ផងដែរ។

**ទេសចរណ៍ជាតិ** គឺជាចង្កោមសកម្មភាពការងារដែលបំរើឲ្យទេសចរណ៍ក្នុងស្រុកនិងទេសចរណ៍ក្រៅប្រទេស។ ដូច្នេះទេសចរណ៍ជាតិជាសកម្មភាពរបស់ជនជាតិប្រទេសមួយដែលអាចធ្វើដំណើរទេសចរណ៍ក្នុងស្រុក ឬ ទេសចរណ៍ក្រៅប្រទេស។[13]

**ទេសចរណ៍ជាតិ** ជាការធ្វើដំណើរកំសាន្តទេសចរណ៍ផ្ទៃក្នុងប្រទេសរបស់ជាតិសាសន៍មួយ និងរាប់បញ្ចូលការធ្វើដំណើរចេញទៅក្រៅប្រទេសរបស់ពួកគេផងដែរ។

[10] en.wikipedia.org/wiki/Domestic Tourism(
[11] www2.unwto.org/agora/some-domestic Tourism
[12] សាកលវិទ្យាល័យភូមិន្ទភ្នំពេញ,សេចក្តីផ្តើមទេសចរណ៍,(មេរៀនសម្រាប់ថ្នាក់បរិញ្ញាប័ត្រទេសចរណ៍ ២០១១),៦
[13] Personal.SocialandHumanities Education Section Education Bureau, Introduction to Tourism , 23

សង្ខេបមក **ទេសចរណ៍ជាតិ** សំដៅលើសកម្មភាពដំណើរកំសាន្តជាទេសចរណ៍របស់ប្រជាពលរដ្ឋនៃជាតិសាសន៍មួយក្នុងទឹកដី និង តំបន់នានានៃប្រទេសនោះ ឬ ចេញទៅក្រៅប្រទេសក្នុងទម្រង់ជាទេសចរណ៍ជាតិរបស់ប្រទេសដើមកំណើត។

រីឯចង្កោមពាក្យ **ទេសចរណ៍អន្តរជាតិ** ជាទូទៅត្រូវបានបែងចែកជាពីរធំៗគឺ Inbound Tourism and Outbound Tourism

**Inbound Tourism**: សំដៅទៅលើជនទាំងឡាយណាដែលធ្វើដំណើរចូលមកកាន់ប្រទេសណាមួយ ហើយស្នាក់នៅទីនោះលើសរយៈពេល ២៤ ម៉ោង តែតិចជាង មួយឆ្នាំ ក្នុងគោលដៅ និងបំណងផ្សេងៗដែលមិនពាក់ព័ន្ធនឹងការស្វែងរកការងារ។

**Outbound Tourism:** សំដៅលើជនទាំងឡាយណាដែលធ្វើដំណើរទៅកាន់ប្រទេសណាមួយ ហើយស្នាក់នៅទីនោះលើសរយៈពេល២៤ម៉ោងតែតិចជាងមួយឆ្នាំ ក្នុងគោលបំណងសំរាកលំហែកាយសិក្សាស្វែងយល់ពោលគឺមិនពាក់ព័ន្ធនឹងការស្វែងរកការងារនិង មិនមែនជាការផ្លាស់ប្តូរកន្លែងរស់នៅ។

**ទេសចរណ៍សង្គម** ( Social Tourism)៖ ជាប្រភេទមួយនៃទេសចរណ៍របស់ជនបរទេសដែលបង្កើតឡើងដោយរដ្ឋាភិបាលសម្រាប់ទ្រទ្រង់ដល់សិស្ស និស្សិត យុវវ័យ អ្នកចូលនិវត្តន៍ ជនពិការ និងប្រជាពលរដ្ឋរបស់ខ្លួនបានចូលរួម ធ្វើដំណើរទេសចរណ៍និងបានធ្វើសកម្មភាពទេសចរណ៍ពិសេសក្នុងរដូវទេសចរតិច។[14]

តាមឯកសាររបស់សាកលវិទ្យាល័យ University of Surrey **ទេសចរណ៍សង្គម** មានន័យថាជាប្រភេទផ្សេងៗគ្នាក្នុងការធ្វើដំណើរនៅថ្ងៃឈប់សំរាក គោលដៅទេសចរណ៍ក្រុមទេសចរណ៍ជាគោលដៅ។ ផ្នត់គំនិតនៃទេសចរណ៍ប្រភេទនេះ ជាប់ពាក់ព័ន្ធនឹងផ្នែកឯកជន និងរដ្ឋាភិបាលដែលមានលក្ខណៈជាពាណិជ្ជកម្ម រួមមាន គម្រោងក្នុងការរៀបចំដំណើរកំសាន្តថ្ងៃឈប់សំរាកជូនកុមារដែលមានជីវភាពក្រីក្រ និងការគិតគូរ ពីសំណាក់អាជ្ញាធរ និងរាជរដ្ឋាភិបាលពីការបង្កើនគុណភាពនៃសេវាសណ្ឋាគារ គុណភាពនៃការីទេសចរណ៍ឯកជនដែលរៀបចំដំណើរកំសាន្តបែបអេកូឡូស៊ីផងដែរ។

ជារួម ទេសចរណ៍សង្គម អាចមានអត្ថន័យជារួមមួយទៀតថា ជាប្រភេទទេសចរណ៍ដែលមានការគិតគូរពិចារណា និងទំនុកបំរុងពីរាជរដ្ឋាភិបាលនៃប្រទេសមួយ ដើម្បីផ្តល់ឱកាសធ្វើដំណើរកំសាន្តទេសចរណ៍ដោយឥតគិតថ្លៃជូន សិស្សនិស្សិត យុវវ័យ កុមារ ជនចូលនិវត្តន៍ ជនពិការ និង

[14] office for National Statistic, Measuring Tourism Locally,

ប្រជាពលរដ្ឋទូទៅរបស់ខ្លួនដែលមានជីវភាពអន់ថយ ឬ មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចំណាយលើការធ្វើដំណើរជាទេសចរណ៍។

## ១.៤.ការចូលរួមនៃវិស័យទេសចរណ៍ក្នុងកំណើនសេដ្ឋកិច្ចបរទេស

ការអភិវឌ្ឍន៍ និង ជម្រុញកំណើនសេដ្ឋកិច្ច គឺជាគោលដៅចម្បងជាមូលដ្ឋានមួយរបស់ប្រទេសទាំងអស់លើពិភពលោក។ ហើយការអភិវឌ្ឍន៍សេដ្ឋកិច្ចនោះដែរគឺត្រូវពឹងផ្អែកលើវិស័យសំខាន់ៗដូចជា៖ វិស័យកសិកម្ម វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យសេវាកម្មនានា។ល។ ដោយក្នុងវិស័យនីមួយៗសុទ្ធតែបានផ្តល់នូវការងារដ៏សម្បូរបែបមកដល់ប្រជាជនក្នុងប្រទេស។ យ៉ាងណាមិញយើងចង់ដឹងថា តើវិស័យទេសចរណ៍បានចូលរួមក្នុងកំណើនសេដ្ឋកិច្ចទៅក្នុងប្រទេសនីមួយៗយ៉ាងណានោះ។ ខាងក្រោមជាករណីសិក្សាអំពីការចូលរួមនៃវិស័យទេសចរណ៍ក្នុងកំណើនសេដ្ឋកិច្ចរបស់បរទេស។

### ១.៤.១. ករណីប្រទេសថៃ

ប្រទេសថៃមានរដ្ឋធានីឈ្មោះ បាងកក ដែលមានប្រជាជនប្រមាណ ៦៧.២ លាននាក់។ រីឯ GDP គឺ ១.១០៨ ពាន់លានដុល្លារ(ppp)ដែលជាទិន្នន័យឆ្នាំ ២០១៦. GDP per capita គឺ ១៥,៣១៩ ដុល្លារសហរដ្ឋអាមេរិក។ GDPទៅតាមវិស័យគឺ វិស័យកសិកម្ម ៨.៤% វិស័យឧស្សាហកម្ម ៣៩.២% និងវិស័យសេវាកម្ម ៥២.៤%។[15]

វិស័យទេសចរណ៍គឺជាដ៏សំខាន់មួយក្នុងព្រះរាជាណាចក្រថៃព្រោះវិស័យនេះបានក្តោបប្រមាណ ២០.៦%នៃGDPសរុបរបស់ថៃក្នុងឆ្នាំ២០១៦នេះឯង។[16]

ក្រាបខាងក្រោមបង្ហាញពីភាគរយនៃGDP ពីមួយឆ្នាំទៅមួយឆ្នាំចាប់ពីឆ្នាំ ២០០៥ ដល់ ឆ្នាំ ២០១៦។ ភាគរយនៃGDPដោយពឹងផ្អែកទៅលើវិស័យទេសចរណ៍របស់ប្រទេសថៃមានការកើនឡើងជាបន្តបន្ទាប់ លើកលែងតែឆ្នាំ២០១០ ដែលយើងសង្កេតឃើញថាវាធ្លាក់ចុះពី ១៥.៩% មកត្រឹមតែ ១៤.២% តែប៉ុណ្ណោះនៃGDPសរុបនៃប្រទេសថៃ។ យ៉ាងណាមិញ នៅឆ្នាំ២០១១ ក៏មានកើនឡើងវិញមកដល់ ១៥.៣% និង នៅតែបន្តកើនឡើងជាបន្តបន្ទាប់រហូតដល់ឆ្នាំ ២០១៦នេះ គេសង្កេតឃើញថាវិស័យទេសចរណ៍បានផ្តល់ចំណូលរហូតដល់ ២០.៦% នៃGDPសរុប។[17]

---

[15] *https://en.wikipedia.org/wiki/Economy_of_Thailand(07/05/2017)*
[16] *https://knoema.com/atlas/thailand/topics/tourism/travel-and-tourism-total-contribution-to-gdp/ (07/05/2017)*
[17] https://knoema.com/atlas/thailand/topics/tourism/travel-and-tourism-total-contribution-to-gdp/total-contribut... *(24/មេសា/២០១៧)*

**ក្រាបទី១.១៖** អត្រាជាភាគរយនៃចំណូលបានមកពីវិស័យទេសចរណ៍ទៅក្នុងសេដ្ឋកិច្ចប្រទេសថៃ




ប្រភព៖ World Data Atlas២០១៦

**តារាងទី១.១៖** ចំនួនភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសថៃ

| ឆ្នាំ | ចំនួនភ្ញៀវទេសចរ | ឆ្នាំ | ចំនួនភ្ញៀវទេសចរ |
|---|---|---|---|
| 2005 | 11,516,936 | 2011 | 19,230,470 |
| 2006 | 13,821,802 | 2012 | 22,353,903 |
| 2007 | 14,464,228 | 2013 | 26,546,725 |
| 2008 | 14,584,220 | 2014 | 24,809,683 |
| 2009 | 14,149,841 | 2015 | 29,881,091 |
| 2010 | 15,936,400 | 2016 | 32,588,303 |

Department of Tourism Thailand 2017

តាមតារាងខាងលើបានបង្ហាញយ៉ាងច្បាស់ អំពីការកើនឡើងនៃចំនួនភ្ញៀវទេសចរណ៍ដែលបានមកកាន់ប្រទេសថៃពីឆ្នាំ២០០៥ ដែលមានភ្ញៀវទេសចរណ៍ត្រឹមតែ ១១,៥១៦,៩៣៦ នាក់ កើនរហូតដល់ទៅ ៣២,៥៨៨,៣០៣ នាក់ក្នុងឆ្នាំ ២០១៦។ ដូចនេះយើងអាចសន្និដ្ឋានបានថាវិស័យទេសចរណ៍របស់ប្រទេសថៃកាន់តែមានការអភិវឌ្ឍន៍ឡើង និងបានបង្កើនចំណូលដល់សេដ្ឋកិច្ចប្រទេសថៃផ្ទាល់ផងដែរ។

## ១.៤.២. ករណីប្រទេសសិង្ហបុរី

ប្រទេសសិង្ហបុរី ជាប្រទេសមួយដែលទទួលបានភ្ញៀវទេសចរបរទេសរហូតដល់ 16,402,593 នាក់ក្នុងឆ្នាំ២០១៦ គឺច្រើនជាងប្រជាជនសរុបប្រមាណជាង ៣ដង ព្រោះចំនួនប្រជាជនសរុប មានត្រឹម 5,607,300 នាក់តែប៉ុណ្ណោះ។ អ្នកទេសចរប្រមាណជា ២១%បានធ្វើដំណើរទេសចរណ៍មិនស្នាក់នៅក្នុងប្រទេសសិង្ហបុរីទេ តែ ៧៩% ទៀតធ្វើការស្នាក់នៅមួយយប់ ឬ ច្រើនជាងនេះ។ ទេសចរដែលមកតាមរយៈផ្លូវអាកាសមាន 77.5% ផ្លូវសមុទ្រមាន10.2% និង ផ្លូវថ្នល់មាន 12.3%។ ចំណែកភ្ញៀវទេសចរណ៍ដែលមានអាយុពី 25-34(22.9%), 35-44(21.3%, 45-54(16.9%)។[18]

**ក្រាបទី១.២៖** អត្រាជាភាគរយនៃចំណូលរបស់វិស័យទេសចរណ៍ទៅក្នុងGDPរបស់ប្រទេសសិង្ហបុរី




ប្រភព៖ World Data Atlas២០១៦

បើតាមក្រាបខាងលើនេះបានបង្ហាញឲ្យឃើញពីការកើនឡើង និង ធ្លាក់ចុះនៃការចូលរួមរបស់វិស័យទេសចរណ៍ទៅក្នុងផលិតផលជាតិសរុបរបស់ប្រទេសសិង្ហបុរី។ បើយោងទៅតាមភាគ

[18] https://en.wikipedia.org/wiki/Tourism_in_Singapore *(២៤/មេសា/២០១៧)*

រយនៃចំណូលរបស់វិស័យទេសចរណ៍ក្នុងឆ្នាំ២០១៦ មានការកើនឡើង ប្រមាណ ០.៩% បើធៀបទៅនឹងភាគរយនៃចំណូលរបស់វិស័យទេសចរណ៍ក្នុងឆ្នាំ២០០៥។

ប៉ុន្តែបើយើងក្រឡេកទៅមើល ភាគរយនៃចំណូលរបស់វិស័យទេសចរណ៍ក្នុងឆ្នាំ ២០១២ វិញគឺមានរហូតដល់ទៅ ១០.៣% ដែលច្រើនជាងឆ្នាំផ្សេងៗទៀត។ ប៉ុន្តែយ៉ាងណាមិញលទ្ធផលដែលទទួលបានក្នុងឆ្នាំ ២០១៦ ក៏មិនមែនអាក្រក់ពេកដែរ ព្រោះវាជាតួរលេខដែលខ្ពស់បន្ទាប់ពីឆ្នាំ ២០១២។

**តារាងទី១.២៖** ចំនួនភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសសិង្ហបុរី

| ឆ្នាំ | ចំនួនភ្ញៀវទេសចរ |
|---|---|
| 2010 | 11,641,700 |
| 2011 | 13,171,303 |
| 2012 | 14,496,091 |
| 2013 | 15,567,923 |
| 2014 | 15,095,152 |
| 2015 | 15,231,469 |
| 2016 | 16,402,593 |

International Visitor Arrival 2016

តាមក្រាបបង្ហាញឲ្យឃើញពីកើនឡើងនៃភ្ញៀវទេសចរដែលក្នុងឆ្នាំ ២០១០មានត្រឹមតែ 11,641,700 ដោយឡែកក្នុងឆ្នាំបន្តបន្ទាប់មានការកើនឡើងបន្តបន្ទាប់ដូចគ្នាហើយក្នុងឆ្នាំ ២០១៦ មានភ្ញៀវរហូតដល់ទៅ 16,402,593។

**១.៣.៣.ករណីប្រទេសចិន**

ប្រទេសចិន ជាប្រទេសដែលមានចំនួនភ្ញៀវទេសចរច្រើនជាងគេលំដាប់ថ្នាក់ទី៣នៅលើពិភពលោក។ ប្រទេសចិនបានរក្សានូវស្ថេរភាពនៃការកើនឡើង ចំនួនភ្ញៀវទេសចរក្នុងឆ្នាំ ២០១៦ ដែលមានប្រមាណជាង ៦៧.៨៧លាននាក់។ រីឯចំណូលបានកើនឡើងទៅដល់ ៥៧៣ពាន់លានដុល្លារសហរដ្ឋអាមេរិក។[19]

(មើលក្រាប ១.៣. នៅទំព័របន្ទាប់)

[19] https://www.travelchinaguide.com/tourism/ *(២៥/មេសា/២០១៧)*

ក្រាបទី១.៣៖ អត្រានៃចំណូលដែលបានពីវិស័យទេសចរណ៍ទៅក្នុងGDPប្រទេសចិន




ប្រភព៖ World Data Atlas២០១៦

អត្រានៃការចូលរួមរបស់វិស័យទេសចរណ៍ទៅក្នុង GDP ឆ្នាំ២០១៦ គឺមាន៩% ដែលវាជាងអត្រាមួយដែលខ្ពស់បើធៀបនឹងឆ្នាំមុនៗ។ ប៉ុន្តែយ៉ាងណាមិញយើងសង្កេតឃើញថាក្នុងឆ្នាំ២០០៦ អត្រានៃចំណូលរបស់វិស័យទេសចរណ៍ទៅក្នុងGDP សរុបមាន ៩.១% ច្រើនជាងឆ្នាំ២០១៦។

**១.៣.៤.ប្រទេសឡាវ**

ក្រាបទី១.៤៖ អត្រាជាភាគរយនៃចំណូលដែលបានពីវិស័យទេសចរណ៍ទៅក្នុងGDPឡាវ




ប្រភព៖ World Data Atlas២០១៦

ប្រទេសឡាវមានGDP ក្នុងឆ្នាំ ២០១៦ប្រមាណ ៩១ ពាន់លានដុល្លាអាមេរិក រីឯ GDP តាមផលិតកម្មវិញគឺ៖ វិស័យសេវាកម្ម មាន ៤២.៦% វិស័យឧស្សាហកម្ម២០.២% និង កសិកម្ម ៣៧.៤% នៃGDPសរុបរបស់ប្រទេសនោះ។[20]

ក្រាហ្វិកខាងលើបានបង្ហាញអំពីការចូលរួមរបស់វិស័យទេសចរណ៍ទៅក្នុង GDP របស់ប្រទេសឡាវ។ ដោយយើងសង្កេតឃើញថាក្នុងរយៈពេល ប្រមាណ៤ឆ្នាំចុងក្រោយ គឺពីឆ្នាំ២០១៣ ដល់ ២០១៦ មានការកើនឡើងប្រហាក់ប្រហែលគ្នា។ ខុសពីឆ្នាំ២០០៥ មានត្រឹមតែ១២.៩%តែប៉ុណ្ណោះ។វិស័យទេសចរណ៍នៅប្រទេសឡាវចាត់ទុកថា ជាឧស្សាហកម្មដែលរីកចម្រើនលឿនមួយ។

**តារាងទី១.៣៖** ស្ថិតិភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសឡាវ

| ឆ្នាំ | ចំនួនភ្ញៀវទេសចរ |
|---|---|
| 2015 | 4,684,429 |
| 2014 | 4,158,719 |
| 2013 | 3,779,490 |
| 2012 | 3,330,072 |
| 2011 | 2,723,564 |
| 2010 | 2,513,028 |
| 2009 | 2,008,363 |

Visitor Statistic of Laos 2015

ក្នុងឆ្នាំ ២០១៥ ចំនួនអ្នកទេសចរណ៍មាន 4,684,429 នាក់ដែលវាជាចំនួនច្រើនមួយបើធៀបនឹងឆ្នាំមុនៗ។ នេះអាចបង្ហាញឲ្យឃើញអំពីសក្តានុពលនៃតំបន់ទេសចរណ៍របស់ប្រទេសឡាវ ដែលអាចទាក់ទាញភ្ញៀវទេសចរណ៍មកទស្សនាពីមួយឆ្នាំទៅមួយឆ្នាំកាន់តែច្រើនឡើងៗ។

### ១.៣.៥.ករណីប្រទេសភីលីពីន

វិស័យទេសចរណ៍ ចាត់ទុកថាជាវិស័យមួយដ៏សំខាន់នៅក្នុងសេដ្ឋកិច្ចប្រទេសភីលីពីន។ក្នុងឆ្នាំ ២០១៥ វិស័យនេះបានផ្តល់ចំណូលទៅក្នុងសេដ្ឋកិច្ចប្រមាណ ១០.៦%។ ប្រទេសភីលីពីនជាប្រជុំកោះ ដែលមានកោះប្រមាណ ៧,៦៤១ កោះ។ ម៉្យាងប្រទេសនេះត្រូវបានគេស្គាល់ថាជាប្រទេសដែលសំបូរទៅដោយជីវចម្រុះ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរ។ មិនតែប៉ុណ្ណោះ ឆ្នេរសមុទ្រ, ភ្នំ, ព្រៃឈើ, កោះ និង កន្លែងមុជទឹក គឺជាទិសដៅទេសចរណ៍ដ៏មាន

[20] *https://en.wikipedia.org/wiki/Economy_of_Laos(07/05/2017)*

ប្រជាប្រិយភាព។ វិស័យនេះបានផ្តល់ការងារដល់ប្រជាជនភីលីពីនប្រមាណ ៤.៩៩ ម៉ឺននាក់ក្នុងឆ្នាំ ២០១៥ និងបានទាក់ទាញភ្ញៀវទេសចរណ៍អន្តរជាតិសរុបប្រមាណ ៥,៣៦០,៦៨២ នាក់។[21]

**ក្រាហ្វិកទី១.៥៖** អត្រាជាភាគរយនៃចំណូលរបស់វិស័យទេសចរណ៍ទៅក្នុង GDP ភីលីពីន




ប្រភព៖ World Data Atlas២០១៦

តាមក្រាបសសរ ខាងលើបានបង្ហាញពីការកើនឡើងនៃអត្រាចំណូលរបស់វិស័យទេសចរណ៍ទៅក្នុង GDP សរុបរបស់ប្រទេសភីលីពីន ដោយការរួមចំណែករបស់វិស័យទេសចរណ៍នេះកាន់តែមានការកើនឡើងទៅក្នុងសេដ្ឋកិច្ចភីលីពីន។

**តារាងទី១.៤៖** ស្ថិតិនៃចំនួនភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសភីលីពីន

| ឆ្នាំ | ចំនួនអ្នកទេសចរ |
|---|---|
| 2006 | 2,843,335 |
| 2007 | 3,091,993 |
| 2008 | 3,139,422 |
| 2009 | 3,017,099 |
| 2010 | 3,520,471 |
| 2011 | 3,917,454 |
| 2012 | 4,272,811 |
| 2013 | 4,681,307 |
| 2014 | 4,833,368 |
| 2015 | 5,360,682 |
| 2016 | 5,967,005 |

Tourism Department of Philippine 2016

[21] https://en.wikipedia.org/wiki/Tourism_in_the_Philippines *(២៥/មេសា/២០១៧)*

រីឯតារាងខាងលើនេះវិញបានបង្ហាញ ពីចំនួនអ្នកទេសចរណ៍ដែលចូលរមកកាន់ប្រទេសភីលីពីនចាប់ពីឆ្នាំ ២០០៦ ដល់ ២០១៦។ នេះបង្ហាញឲ្យកាន់តែច្បាស់ថាភីលីពីនបានទាក់ទាញភ្ញៀវទេសចរណ៍ឲ្យមក ទស្សនាក្នុងប្រទេសខ្លួនកាន់តែច្រើនឡើងៗ។

តាមរយៈការសិក្សាស្រាវជ្រាវ អំពីវិស័យទេសចរណ៍ក្នុងប្រទេសចំនួន៥ខាងលើ បង្ហាញឲ្យឃើញថាវិស័យទេសចរណ៍ពិតជាបានចូលរួមចំណែក ទៅក្នុងកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំរបស់ប្រទេសនីមួយៗមែន។ ហេតុដូចនេះហើយបណ្តាប្រទេសស្ទើតែទាំងអស់បានខិតខំអភិវឌ្ឍន៍វិស័យនេះបន្តទៀត ដើម្បីជម្រុញបន្ថែមនូវកំណើនសេដ្ឋកិច្ចក្នុងប្រទេសរបស់ខ្លួន។

# ជំពូកទី២
# សេដ្ឋកិច្ចកម្ពុជា និង
# វិស័យទេសចរណ៍

# ជំពូកទី២ សេដ្ឋកិច្ចកម្ពុជា និង វិស័យទេសចរណ៍

## ២.១. ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

សេដ្ឋកិច្ចកម្ពុជា នៅតែបន្តរក្សាបានកំណើនរឹងមាំក្នុងរង្វង់ ៧% ក្នុងឆ្នាំ ២០១៧ ដោយពឹងផ្អែកទៅលើ វិស័យដូចជា៖ វិស័យកសិកម្ម, វិស័យកាត់ដេរ, វិស័យឧស្សាហកម្មមិនមែនកាត់ដេរ,វិស័យសំណង់, វិស័យលក់ដុំ និង លក់រាយ ព្រមទាំងវិស័យសេវាកម្មផងដែរ។[22]

តាមរបាយការណ៍ថ្មីមួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលចេញផ្សាយនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៧ បានឲ្យដឹងថា សេដ្ឋកិច្ចរបស់កម្ពុជាត្រូវបានគេរំពឹងថា នឹងនៅតែមានភាពរឹងមាំ ក្នុងរយៈពេល ២ឆ្នាំបន្តទៀត ដោយសារតែភាពរឹងមាំ នៃការនាំចេញសំលៀកបំពាក់ និងស្បែកជើង សកម្មភាពក្នុងវិស័យសំណង់ និងអចលនទ្រព្យ និងការកើនឡើងនូវចំណាយរបស់រដ្ឋាភិបាល គួបផ្សំនឹងការងើបឡើងវិញក្នុងកម្រិតមធ្យមនៃផលិតកម្មកសិកម្ម។ របាយការណ៍ដដែលលើកឡើងថា ផលិតផលសរុបក្នុងស្រុក (ផ.ស.ស) នឹងកើនឡើងដល់ ៧,១ភាគរយ ក្នុងឆ្នាំ ២០១៧ និងឆ្នាំ ២០១៨ ពោលគឺខ្ពស់ជាងតួរលេខប៉ាន់ប្រមាណ ៧,0 ភាគរយ ក្នុងឆ្នាំ ២០១៦ បន្តិច។ លោក Samiuela Tukuafu នាយក ADB ប្រចាំប្រទេសកម្ពុជាមានប្រសាសន៍ថា “ខណៈដែលទស្សនវិស័យកំណើនសេដ្ឋកិច្ចរយៈពេលខ្លីរបស់កម្ពុជា នៅតែមានភាពរឹងមាំ ថ្លៃឈ្នួលពលកម្ម និងកង្វះជំនាញនៅតែមានការកើនឡើង។ ការពន្លឿនការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ នឹងកាត់បន្ថយចំណាយសម្រាប់ការធ្វើធុរកិច្ច និងបង្កើនកំណើនផលិតភាពនិងភាពប្រកួតប្រជែងរបស់ប្រទេសនេះ តាមរយៈកំណែទម្រង់លិខិតបទដ្ឋានគតិយុត្តិ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ភស្តុភារ និងជំនាញផ្សេងៗមួយចំនួនទៀត”។ តាមលោក Samiuela Tukuafu កំណើនវិស័យឧស្សាហកម្ម ត្រូវបានព្យាករថា នឹងមានអត្រាខ្ពស់ជាងមុនបន្តិច ពោលគឺ១០,៨ភាគរយនៅឆ្នាំនេះ ដោយសារប្រទេសឧស្សាហកម្មធំៗមួយចំនួនមានកំណើនខ្ពស់ជាងមុន និងការធ្វើពិពិធកម្មទៅរកផលិតផល ដែលមានតម្លៃបន្ថែមខ្ពស់ ដូចជា សំលៀកបំពាក់ ស្បែកជើង កម្មន្តសាលធុនស្រាល និងអេឡិចត្រូនិក ជាដើម។ វិស័យសេវាកម្មត្រូវបានរំពឹងថា នឹងកើនឡើង ៦,៧ភាគរយ ដោយសារតែការកើនឡើងខ្ពស់នៃតម្រូវការក្នុងស្រុក និងវិស័យទេសចរណ៍។ ចំណែកវិស័យកសិកម្មវិញ នឹងកើនឡើង១,៨ភាគរយដោយសន្មតថាអាកាសធាតុនឹងមានលក្ខណៈអំណោយផល។ វិស័យសំណ

[22] ក្រសួងសេដ្ឋកិច្ច និង ហារិញ្ញវត្ថុ២០១៦ និង ២០១៧

ង់ត្រូវបានរំពឹងថានឹងមានកំណើនមធ្យម។ខាងក្រោមយើងនឹងបង្ហាញពី កំណើនវិស័យនានាដែលចូលរួមក្នុងកំណើនសេដ្ឋកិច្ចជាតិ។

### ២.១.១.វិស័យកសិកម្មក្នុងប្រទេសកម្ពុជា

វិស័យកសិកម្មរក្សាបានលំនឹងយ៉ាងរឹងមាំ ដោយសារភាពអំណោយផលនៃអាកាសធាតុ គោលនយោបាយវិត្តារកម្ម និង ការចូលរួមកាន់តែសកម្មជាងមុន ពីសំណាក់ដៃគូអភិវឌ្ឍន៍ និង វិស័យឯកជន ។

**ក្រាបទី២.១៖ កំណើនវិស័យកសិកម្មក្នុងប្រទេសកម្ពុជា**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ ២០១៦ និង ២០១៧

| | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017ព្យ |
|---|---|---|---|---|---|---|---|
| នេសាទ | 3.1 | 6.7 | 5.4 | 0.1 | 0.3 | 1.8 | 2.6 |
| ដំណាំ | 4.3 | 4.9 | 0.6 | 0.5 | 0.3 | 2.2 | 2.1 |
| ការចិញ្ចឹមសត្វ | 0.2 | 0.8 | 0.1 | 0.2 | 0 | 0.5 | 1.4 |
| ព្រៃឈើ | -0.1 | -2.5 | -2.9 | -1.2 | -0.8 | -1.6 | -1.7 |
| កសិកម្ម | 3.1 | 4.3 | 1.6 | 0.3 | 0.2 | 1.8 | 2 |

ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ ២០១៦ និង ២០១៧

### ២.១.២. វិស័យឧស្សាហកម្ម

វិស័យឧស្សាហកម្ម នៅតែរក្សាបានកំណើនពីរខ្ទង់ ដោយសារកំណើនរឹងមាំ នៃវិស័យកាត់ដេរ បន្តកំណើនខ្ពស់ នៃអនុវិស័យឧស្សាហកម្មផ្សេងទៀត ទោះបីជាវិស័យសំណង់បន្តថមថយកំណើនក៏ដោយ។

**ក្រាបទី២.២៖ កំណើនវិស័យឧស្សាហកម្មក្នុងប្រទេសកម្ពុជា**




<u>ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ និង ក្រសួងហិរញ្ញវត្ថុ ២០១៦ និង ២០១៧</u>

### ២.១.៣. វិស័យពាណិជ្ជកម្ម

កំណើនពាណិជ្ជកម្មអន្តរជាតិ ជាផ្នែកមួយនៃការជម្រុញកំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាផងដែរ។ ក្រាបខាងក្រោមនឹងបង្ហាញអ្នកអំពី កំណើននៃការនាំចេញនៃរបស់ប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៦។

(មើលក្រាប ២.៣ នៅទំព័របន្ទាប់)

ក្រាបទី២.៣ ៖ កំណើនពាណិជ្ជកម្មក្នុប្រទេសកម្ពុជា




ប្រភព៖ ក្រសួងពាណិជ្ជកម្ម ឆ្នាំ២០១១-២០១៦

## ២.១.៤. វិស័យសំណង់

វិស័យសំណង់ក្នុងប្រទេសកម្ពុជា មានការថមថយបន្តិចក្តី តែទោះបីជាយ៉ាងណាក៏ស្ថិតនៅក្នុងគន្លងមួយដែលមាននិរន្តភាព។

ក្រាបទី២.៤ ៖ កំណើនវិស័យសំណង់ក្នុប្រទេសកម្ពុជា




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងហិរញ្ញវត្ថុ ២០១៦ និង ២០១៧

### ២.១.៥. វិស័យសេវាកម្ម

វិស័យសេវាកម្មផ្តោតសំខាន់ទៅលើ វិស័យទេសចរណ៍, លក់ដុំ និង លក់រាយ, ការដឹកជញ្ជូន និង គមនាគមន៍, អចលទ្រព្យ និង ព្រមទាំងអនុវិស័យដទៃទៀត។

#### ២.១.៥.១. វិស័យទេសចរណ៍

បើយោងតាមអត្ថបទនិយាយអំពី « ស្ថានភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន និង ទស្សនវិស័យឆ្នាំ ២០១៨ » ថ្ងៃទី ០៨ខែឧសភា ឆ្នាំ ២០១៧ បានបង្ហាញថា វិស័យទេសចរណ៍ អាចនឹងបន្តកំណើនយឺត ដោយផ្អែកលើកត្តាចំណាយ និង រយៈពេលស្នាក់នៅ ទោះបីភ្ញៀវទេសចរអន្តរជាតិមានកំណើនប្រសើរជាងមុនក៏ដោយ។

ក្រាបទី២.៥៖កំណើនវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា




ប្រភព៖ ក្រសួងទេសចរណ៍ ២០១៦ និង ២០១៧

#### ២.១.៥.២. វិស័យដឹកជញ្ជូន និង ទូរគមនាគមន៍

វិស័យដឹកជញ្ជូននៅតែបន្ត កំណើនប្រហាក់ប្រហែល នឹងឆ្នាំទៅដោយសារកំណើនយឺតនៃអនុវិស័យឧស្សាហកម្មមួយចំនួន។

**ក្រាបទី២.៦ ៖ កំណើនវិស័យដឹកជញ្ជូន និង ទូរគមនាគមន៍**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ២០១៦ និង ២០១៧

### ២.១.៥.៣. វិស័យអចលទ្រព្យ

ភាពយឺតជាងមុននៃប្រភពទុន និងការខិតជិតនៃឆ្នាំបោះឆ្នោតអាចធ្វើឲ្យមានភាពស្ទាក់ស្ទើក្នុងការវិនិយោគបន្ថែមទៅលើវិស័យអចលទ្រព្យ ក្នុងបរិបទនៃភាពមិនច្បាស់លាស់នៃស្ថានភាពហិរញ្ញវត្ថុជាសកល។

**ក្រាបទី២.៧ ៖ កំណើនវិស័យអចលទ្រព្យក្នុងប្រទេសកម្ពុជា**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ២០១៦ និង ២០១៧

**២.១.៥.៤. វិស័យលក់ដុំ និង លក់រាយ**

វិស័យលក់ដុំ និង លក់រាយ នៅតែបន្តកំណើនរឹងមាំ ដែលគាំទ្រដោយការបន្តកើនឡើងនៃប្រាក់បៀវត្សន៍អប្បបរមា និង គោលនយោបាយវិត្ថារកម្មរបស់រាជរដ្ឋាភិបាល ទោះបីឥណទាននៃវិស័យនេះមានការថមថយ។

**ក្រាបទី២.៨ ៖ កំណើនវិស័យលក់ដុំ និង លក់រាយ**




ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ, ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ, ២០១៦ និង ២០១៧

សរុបសេចក្តីមក យោងតាមអត្ថបទនិយាយអំពី "ស្ថានភាពសេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន និងទស្សនវិស័យឆ្នាំ ២០១៨" បានបង្ហាញឲ្យឃើញអំពីស្ថានភាពសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ន និង ទស្សនវិស័យសេដ្ឋកិច្ចកម្ពុជានៅឆ្នាំខាងមុខដូចខាងក្រោម៖

**តារាងទី២.១ ៖ កំណើនផសស និង កំណើនវិស័យនានា**

| | ២០១៦ប៉ាន់. | ២០១៧ ព្យ. | ២០១៨ ព្យ. |
|---|---|---|---|
| **កំណើន ផសស តាមថ្លៃថេរ(កំណើនជា%)** | 7% | 7% | 7% |
| **វិស័យកសិកម្ម** | 1.84% | 1.90% | 1.99% |
| ដំណាំ | 2.25% | 2.10% | 1.93% |
| **វិស័យឧស្សាហកម្ម** | 10.55% | 10.69% | 10.11% |
| កាត់ដេរ | 8.02% | 8.45% | 7.95% |
| សំណង់ | 14.90% | 14.10% | 12.36% |
| ឧស្សាហកម្មផ្សេងៗ | 11.56% | 12.72% | 12.97% |

| | | | |
|---|---|---|---|
| **វិស័យសេវាកម្ម** | 6.66% | 6.53% | 6.66% |
| លក់ដុំ និង រាយ | 7.43% | 7.76% | 8.27% |
| ទេសចរណ៍ | 2.23% | 2.34% | 2.27% |
| ដឹកជញ្ជូន និង គមនាគមន៍ | 7.64% | 7.49% | 7.41% |
| អចលទ្រព្យ និង ពាណិជ្ជកម្ម | 9.49% | 8.25% | 7.94% |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ២០១៦ និង ២០១៧

តារាងខាងលើបានបង្ហាញថាកំណើន ផលិតផលក្នុងស្រុកសរុប (ផសស) ក្នុងឆ្នាំ ២០១៦ មានកំណើន៧% ហើយក្នុងការព្យាករណ៍ឆ្នាំ ២០១៧ និង ២០១៨ នៅតែរក្សារកំណើន ៧% ដដែល។ វិស័យកសិកម្មមានកំណើន ១.៨៥% វិស័យឧស្សាហកម្មកាត់ដេរមានកំណើន ៨.០២% ឧស្សាហកម្មសំណង់ មានកំណើន១៥.៩% វិស័យលក់ដុំ និងរាយ មានកំណើន ៧.៤៣% វិស័យទេសចរណ៍ មានកំណើន ២.២៣% វិស័យដឹកជញ្ជូន និង គមនាគមន៍ ៧.៦៤% វិស័យអចលទ្រព្យ និង ពាណិជ្ជកម្ម ៩.៤៩% ដែលជាអត្រាកំណើនក្នុងឆ្នាំ ២០១៦។

## ២.២.ប្រវត្តិនៃការកើតឡើងនូវការធ្វើដំណើរទេសចរណ៍

ពាក្យថា «ទេសចរណ៍» មានន័យទូលំទូលាយណាស់ ហើយនិយមន័យរបស់វាត្រូវបានគេជួបប្រទះនៅក្នុងលក្ខណៈ ផ្សេងៗគ្នាជាច្រើនទៅតាមប្រភេទអ្នកនិពន្ធ និង ប្រភេទនៃឯកសារ។ ពាក្យ « ទេសចរណ៍» កើតចេញពីពាក្យភាសាអង់គ្លេស ហៅថា « Tourism » មានន័យថាការដើរកំសាន្តចេញពីកន្លែងណាមួយ តាមមធ្យោបាយផ្សេងៗដូចជាធ្វើដំណើរដោយថ្មើជើង ជិះរទេះ ជិះសត្វពាហនៈ ឬ ដោយមធ្យោបាយយានជំនិះណាមួយ ក្រោយអំពីបានបញ្ចប់ការងារ ឬ សកម្មភាពរបស់ពួកគេ។

ក្រោយមកមានការកំណត់ផ្សេងទៀតដែលថាទេសចរណ៍ជាការធ្វើដំណើរ ឬ ជាការធ្វើចលនារបស់ពលរដ្ឋដែលមិនទាក់ទងអ្វីទៅនឹងការផ្លាស់ប្តូរទីលំនៅ ឬ ការផ្លាស់ប្តូរទីកន្លែងដើម្បីស្វែងរកការងារធ្វើនោះឡើយ គឺបានសេចក្តីថាពួកគេធ្វើដំណើរ ក្នុងគោលបំណងដើម្បីស្វែងរកការសម្រាកលំហែ និង កំដរអារម្មណ៍ក្រោយពីមានការនឿយហត់ ក្នុងការបំពេញការងា។

សេចក្តីដូចបានរៀបរាប់ខាងលើ បង្ហាញឲ្យឃើញថាទេសចរណ៍កើតឡើងដោយការធ្វើដំណើរ ហើយវាបានរីកចម្រើនពីមួយទៅថ្ងៃទៅមួយថ្ងៃ ដែលជាហេតុធ្វើឲ្យមានការកកើតឡើងនូវសកម្មភាពថ្មីមួយទៀត ដែលទាមទារឲ្យមានការរៀបចំនូវកន្លែងស្នាក់នៅ អាហារ និង ភេសជ្ជៈសម្រាប់ទទួលទាន និង ការលំហែកម្សាន្ត។

ពាក្យថាការធ្វើដំណើរ "ទេសចរណ៍" មានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងគ្នានិងគ្នា ដោយពុំអាចបំបែកចេញបានទេក្នុងជីវភាពរស់នៅ ក្នុងសង្គមរបស់មនុស្ស ពីព្រោះថាវាជាការចាំបាច់បំផុតដែលមនុស្សគ្រប់រូបត្រូវការ។ គេពុំអាចកំណត់ឲ្យបានច្បាស់លាស់បានទេអំពីការកកើតឡើងនៃការធ្វើដំណើរ។ តែគេគ្រាន់តែដឹងថា វាបានកើតឡើងតាំងពីយុគសម័យដំបូង នៅពេលដែលមនុស្សបានចាប់កំណើត នៅលើផែនដីយើងនេះ។ ក្នុងសភាពរស់នៅដោយពឹងផ្អែកលើធម្មជាតិ មនុស្សត្រូវការ បង្កើតឡើងនូវសម្ភារៈសម្រាប់ធ្វើការងារ ការស្វែងរកអាហារ ដើម្បីមកផ្គត់ផ្គង់គ្រួសាររបស់ពួកគេ ហើយថែមទាំងមានការបំលាស់ទីពីកន្លែងមួយទៅកន្លែងមួយ ដើម្បីប្រយុទ្ធប្រឆាំង នឹងការគំរាមគំហែងពីធម្មជាតិ។ ការរស់នៅបែបនេះបានផ្តល់ជាសញ្ញាថាជាការរស់នៅបែបធម្មជាតិទាំងស្រុងរួមមានសកម្មភាព សេដ្ឋកិច្ច ដើម្បីទ្រទ្រង់ជីវិត និង ការធ្វើដំណើរផ្លាស់ប្តូរទីកន្លែងដើម្បីគេចចេញពីគ្រោះថ្នាក់នានារបស់ធម្មជាតិ។

ការយល់ដឹងអំពីបរិស្ថាននៅជុំវិញជាលើកដំបូងបានកើតឡើងនៅពេលដែលមនុស្សបានធ្វើដំណើរចាកចេញពីតំបន់មួយទៅតំបន់មួយទៀត ដើម្បីស្វែងរកអាហារចិញ្ចឹមជីវិត ហើយនៅពេលដែលសត្វពាហនៈបានកើតឡើង ពួកគេបានដើរស្វែងរកអាហារសម្រាប់សត្វទាំងនោះដូចជាវាលស្មៅជាដើម។ ការវិវឌ្ឍចេះតែទៅមុខពីមួយថ្ងៃទៅមួយថ្ងៃ។ ការធ្វើដំណើរស្វែងរកអាហារចេះតែលំបាក ដែលបណ្តាលឲ្យពួកគេធ្វើដំណើរកាន់តែឆ្ងាយឡើងៗ ដើម្បីស្វែងរកកន្លែងដែលមានលទ្ធភាពឲ្យពួកគេរស់នៅបាន។ តាមរយៈការសិក្សាស្រាវជ្រាវរបស់ទស្សនៈវិទូ និង ប្រវត្តិវិទូគេបានសន្និដ្ឋានថា ចាត់តាំងពីពេលកើតឡើងរបស់មនុស្សមក មនុស្សរស់នៅក្នុងតំបន់មួយ បានតែរយៈពេលខ្លីប៉ុណ្ណោះព្រោះពួកគេ ត្រូវធ្វើដំណើរ ដើម្បីស្វែងរកដីមានជីវជាតិសម្រាប់ធ្វើចំការដើម្បីទ្រទ្រង់ជីវភាពរបស់ពួកគេឲ្យប្រសើរឡើង។

នៅពេលដែលមានការកកើតឡើង កុលសម្ព័ន្ធផ្សេងៗ ពួកគេបានបង្កើតជាផ្លូវដើម្បី ងាយស្រួលក្នុងការប្រាស្រ័យទាក់ទងគ្នា ពីកុលសម្ព័ន្ធមួយទៅកុលសម្ព័ន្ធមួយ ពីតំបន់មួយទៅតំបន់មួយហើយការធ្វើដំណើរទៀតសោតច្រើនតែតាមមធ្យោបាយផ្លូវគោក។ ការធ្វើដំណើរតាមផ្លូវគោកនេះបានបន្សល់នូវស្លាកស្នាមជាច្រើន ដែលគេបានធ្វើជាសញ្ញាសំគាល់ក្នុងការធ្វើដំណើរ។

សរុបសេចក្តីមកចាប់តាំងពីការកកើតឡើង នៃមនុស្សមកគេបានបង្កើតផ្លូវជាច្រើនសម្រាប់ទំនាក់ទំនងគ្នាក្នុងសកម្មភពសេដ្ឋកិច្ចដើម្បីទ្រទ្រង់ជីវិត និង ផ្លាស់ប្តូរទីលំនៅ។ តែក្រោយមក ដើម្បីឲ្យការរស់នៅមានលក្ខណៈកាន់តែងាយស្រួលឡើងគេបានបង្កើតឲ្យមានការកសាង ផ្លូវលំ ផ្លូវជាតិតូច ធំ ផ្លូវរថភ្លើង ដែល មានរហូតមកដល់សព្វថ្ងៃនេះ។

សាសនាក៏ជាកត្តាចម្បងមួយ ក្នុងការជម្រុញឲ្យមានការរីកចម្រើនក្នុងការធ្វើដំណើរ ហើយអ្នកសាសនាទាំងនោះ បានខិតខំបំពេញគោលបំណងរបស់ខ្លួនដោយធ្វើដំណើរពីតំបន់មួយទៅតំបន់មួយ ដើម្បីផ្សព្វផ្សាយសាសនារបស់ពួកគេឲ្យទៅជាតិសាសន៍ដទៃ។ ក្នុងដំណាក់កាលសព្វថ្ងៃនេះសាសនាបានទាក់ទាញ និង ក្លាយជាកត្តាមួយដ៏ចម្បងសម្រាប់ធ្វើឲ្យលូតលាស់ដល់ផ្នែកទេសចរណ៍។ ទីកន្លែងជួបជុំអ្នកដឹកនាំសាសនាធំៗនៅក្នុងពិភពលោកសព្វថ្ងៃនេះ បានក្លាយទៅជាតំបន់ទេសចរណ៍បែបសាសនាយ៉ាងធំ ដែលមួយឆ្នាំៗ មានភ្ញៀវទេសចររាប់លាននាក់ទៅធ្វើការបួងសួងដើម្បីសុំសេចក្តីសុខ និង ទស្សនា ដូចតំបន់សាសនាអ៊ីស្លាម នៅតំបន់នៃ អារ៉ាប៊ីសាវឌីត និង សាសនាគ្រិស្តនៅទីក្រុង យេរូសាឡិមប្រទេស អ៊ីស្រាអែលជាដើម។

ចំពោះពាក្យ "បដិសណ្ឋារកិច្ច" គឺជាពាក្យដែលមានប្រភពចេញពីភាសាអង់គ្លេស (Hospitality) ដែលមានន័យថាការទទួលសំណាក់អាស្រ័យចំពោះអ្នកធ្វើដំណើរ និង អ្នកទេសចរជាដើម។ តាមពិតសកម្មភាពទាំងនេះវាបានកើតឡើងដំណាលគ្នា ជាមួយនិងការធ្វើដំណើរទេសចរណ៍មកម្ល៉េះប៉ុន្តែមិនទាន់ត្រូវបានយកចិត្តទុកដាក់ឲ្យបានខ្លាំងក្លានោះទេ ទើបតែនៅពីរបីសតវត្សន៍ចុងក្រោយនេះ ពាក្យនេះត្រូវបានគេយកចិត្តទុកដាក់យ៉ាងខ្លាំង សម្រាប់ប្រតិបត្តិករសេវាកម្មទេសចរណ៍។ បដិសណ្ឋារកិច្ចសំដៅលើសកម្មភាពសេវាកម្ម ដែលមានគោលដៅបំពេញនូវសេចក្តីត្រូវការ ដល់អ្នកធ្វើដំណើរទេសចរណ៍ ពោលគឺសកម្មភាពដែលធ្វើឲ្យអ្នកដំណើរទេសចរណ៍មានភាពកាន់តែងាយស្រួលឡើងៗ ក្នុងដំណើរសេដ្ឋកិច្ច ឬ ក្នុងដំណើរការ ដើម្បីបំពេញការងារពាណិជ្ជកម្មជាដើម។

ជាសរុប យើងអាចសន្និដ្ឋានបានថា "ការធ្វើដំណើរទេសចរណ៍" និង "បដិសណ្ឋារកិច្ច" បានកើតឡើងក្នុងពេលដំណាលគ្នា និង ឆ្លងកាត់នូវដំណាក់កាលវិវត្តន៍ដូចគ្នា។ នៅក្នុងពេលបច្ចុប្បន្ននេះ ពិភពលោកបានយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅដល់ការធ្វើដំណើរជាទេសចរណ៍របស់មនុស្សហេតុដូច្នេះហើយបានជាប្រទេសទូទាំងសាកលលោក បង្កើតស្ថាប័នទេសចរណ៍ឡើង ក្នុងគោលដៅអភិវឌ្ឍន៍វិស័យនេះឲ្យប្រកបដោយចីរភាព។[23]

## ២.៣. ស្ថានភាពទេសចរណ៍ក្នុងប្រទេសកម្ពុជា

វិស័យទេសចរណ៍នៅកម្ពុជា ត្រូវបានគេមើលឃើញថាជាវិស័យដែលមានអាទិភាពមួយដែរនៃសេដ្ឋកិច្ចទោះបីជាក្នុងរយៈចុងក្រោយនេះយើងសង្កេតឃើញថា វិស័យទេសចរណ៍ពុំសូវជាមាន

[23] សេចក្តីផ្តើមទេសចរណ៍(២០១៨) រៀបរៀងដោយ បណ្ឌិត ឈុន ពហុ, អនុបណ្ឌិត ជា ស៊ីថា, ហាង វណ្ណៈ និង សាំង ចន្ទូ / ទំព័រទី ២២ ដល់ ២៧

កំណើនខ្លាំងក៏ដោយ បើធៀបនឹងឆ្នាំមុនៗ ។ វាជាប្រភពនៃចំណូល ហើយក៏ជាផ្នែកមួយនៃការអភិវឌ្ឍន៍សេដ្ឋកិច្ច។ ម៉្យាងវិញទៀតវិស័យទេសចរណ៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាជាមាសបៃតង និង ជាការនាំចេញនៅនឹងកន្លែង។ វិស័យនេះចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច និង សង្គមតាមរយៈការបង្កើតប្រាក់ចំណូលជូនជាតិ បង្កើតការងារ ជម្រុញការវិនិយោគ និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។ លើសពីនេះទៀតប្រទេស ចូលរួមកាត់បន្ថយការកើនឡើងនៃកំដៅភពផែនដី និង ជាកាតាលីករមួយដ៏សំខាន់ក្នុងការជម្រុញសាកលភាវូបនីយកម្ម និងសមាហរណកម្ម តំបន់ផងដែរ។

ដោយផ្អែកលើកត្តាសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ និង សុវត្ថិភាពពេញផ្ទៃប្រទេស និងក្រោមការផ្សព្វផ្សាយ "កម្ពុជា ព្រះរាជាណាចក្រអច្ឆរិយៈ" នៅឆ្នាំ ២០១៥កន្លងទៅ កម្ពុជាបានទទួលភ្ញៀវទេសចរណ៍អន្តរជាតិចំនួន ៤.៨លាននាក់ កើន ៦.១% នាំចំណូលជូនជាតិប្រមាណជាង ៣ពាន់ដុល្លាស្មើនឹង ១៣%នៃផលិតផលក្នុងស្រុកសរុប(GDP) បង្កើតការងារផ្ទាល់ប្រមាណជាង ៦២ម៉ឺនការងារ ស្មើនឹង១៣% នៃកម្លាំងពលកម្មសរុប ព្រមទាំងការងារមិនផ្ទាល់រាប់សិបម៉ឺននាក់ទៀត។ ឆ្នាំ២០១៦នេះ កម្ពុជាទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ ជាង៥លាននាក់ រីឯដើមឆ្នាំ ២០១៧ ក្នុងរយៈពេល២ខែ គឺខែ មករា និង កុម្ភៈ ឯនេះវិញទទួលបានភ្ញៀវទេសចរអន្តរជាតិប្រមាណ ជាង ១លាននាក់ទៅហើយ។

## ២.៤. ស្ថិតិទេសចរណ៍កម្ពុជា

### ២.៤.១.ស្ថិតិទេសចរណ៍ Inbound និង Outbound

អ្នកបាននឹងរួចមកហើយថា Inbound Tourism និង Outbound Tourism ថាតើមានភាពខុសគ្នាយ៉ាងណានោះ។ ដូចនេះយើងខ្ញុំសូមនិយាយជាសង្ខេបម្តងទៀត Inbound Tourism សំដៅលើភ្ញៀវទេសចរណ៍ទាំងឡាយដែលចូលមកកាន់ប្រទេសយើង។ រីឯ Outbound Tourism វិញសំដៅលើប្រជាជនទាំងឡាយណាដែលធ្វើដំណើរទៅកាន់បរទេស។

#### ២.៤.១.១.ស្ថិតិទេសចរណ៍ Inbound

នេះគឺជាទិន្នន័យនៃទេសចរអន្តរជាតិ ដែលធ្វើដំណើរមកកាន់ប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០១១ ដល់ ២០១៦។

**តារាងទី២.២៖ ចំនួនភ្ញៀវទេសចរណ៍ដែលចូលមកកាន់ប្រទេសកម្ពុជា ពីឆ្នាំ២០១១ ដល់ ២០១៦**

| ខែ | 2011 | 2012 | 2013 | 2014 | 2015 | 2016 |
|---|---|---|---|---|---|---|
| **Q1** | **778,467** | **995,210** | **1,172,572** | **1,267,922** | **1,307,836** | **1,342,477** |
| មករា | 274,471 | 350,257 | 404,106 | 442,045 | 460,577 | 466,086 |
| កុម្ភៈ | 255,499 | 321,870 | 385,760 | 425,801 | 430,207 | 448,468 |
| មីនា | 248,497 | 323,083 | 382,706 | 400,076 | 417,052 | 427,923 |
| **Q2** | **606,562** | **761,442** | **920,527** | **933,446** | **994,154** | **1,018,455** |
| មេសា | 223,032 | 277,304 | 327,000 | 332,690 | 361,139 | 367,684 |
| ឧសភា | 190,258 | 233,220 | 292,115 | 300,302 | 314,748 | 320,601 |
| មិថុនា | 193,272 | 250,918 | 301,412 | 300,454 | 318,267 | 330,170 |
| **Q3** | **699,760** | **820,888** | **964,612** | **998,690** | **1,044,880** | **1,147,483** |
| កក្កដា | 239,527 | 284,282 | 338,761 | 340,091 | 364,325 | 395,761 |
| សីហា | 250,429 | 293,859 | 342,064 | 347,211 | 366,096 | 406,214 |
| កញ្ញា | 209,804 | 242,747 | 283,787 | 311,388 | 314,459 | 345,508 |
| **Q4** | **797,073** | **1,006,767** | **1,152,954** | **1,302,717** | **1,428,361** | **1,503,297** |
| តុលា | 233,190 | 290,959 | 334,410 | 390,637 | 408,922 | 414,077 |
| វិច្ឆការ | 265,539 | 333,482 | 386,737 | 411,501 | 444,640 | 477,686 |
| ធ្នូ | 298,344 | 382,326 | 431,807 | 500,579 | 574,799 | 611,534 |
| **សរុប** | **2,881,862** | **3,584,307** | **4,210,665** | **4,502,775** | **4,775,231** | **5,011,712** |

ប្រភព៖ Tourism Statistic Department, MOT,2016

តាមតារាងបង្ហាញយ៉ាងច្បាស់អំពីកំណើននៃចំនួនភ្ញៀវទេសចរអន្តរជាតិពីឆ្នាំ ២០១១ ដល់ ២០១៦ ដែលវាបង្ហាញអំពី សក្តានុពលនៃតំបន់ទេសចរណ៍ក្នុងប្រទេសយើង។ ដើម្បីយល់ច្បាស់

អំពីកំណើននេះយើង នឹងធ្វើការបង្ហាញពីក្រាហ្វិកវិញម្តង ថាតើកំណើននេះមានសភាពយ៉ាងណានោះ។

**ក្រាបទី២.៩ ៖ បង្ហាញពីចំនួននៃភ្ញៀវទេសចរណ៍ពីឆ្នាំ២០១១ដល់២០១៦ ចាប់ពីខែមករា ដល់ ធ្នូ**




ប្រភព៖ Statistics and Tourism Information Department, MOT2016

ក្រាហ្វិកបានបង្ហាញអំពីកំណើនភ្ញៀវទេសចរពីខែមករា ដល់ ខែធ្នូ ចាប់ពីឆ្នា ២០១១មកដល់ ២០១៦។ យើងខ្ញុំសូមធ្វើការបកស្រាយទៅខ្សែកោងពណ៌ទឹកក្រូច ដែលតំណាងឲ្យឆ្នាំ ២០១៦តែម្តង។ ខ្សែកោងនេះបានបង្ហាញថាក្នុងខែមករាមាន ភ្ញៀវទេសចរបរទេសប្រមាណជាជិត ៥០០,០០០នាក់ ប៉ុន្តែហាក់មានការធ្លាក់ចុះជាបន្តបន្ទាប់ ពីខែកុម្ភៈ រហូតដល់ខែឧសភាមានការធ្លាក់ចុះខ្លាំង បានត្រឹមតែ ៣២០,៦០១ នាក់តែប៉ុណ្ណោះ។ ដែលនេះប្រហែលជាមកពីកត្តាផ្សេងៗ ដូចជាអាកាសធាតុជាដើម។ យ៉ាងណាមិញក្នុងខែមិថុនា ចំនួនភ្ញៀវទេសចរចាប់ផ្តើមកើនឡើងបន្តិចម្តងៗឡើងវិញទោះបីជាមានការធ្លាក់ចុះ បន្តិចបន្តួចក្តីក្នុង ខែកញ្ញា។ ប៉ុន្តែបន្ទាប់ពីខែកញ្ញាយើងឃើញថាខ្សែកោងមានសន្ទុះយ៉ាងលឿន និង កើនឡើងយ៉ាងខ្ពស់បំផុតក្នុងខែធ្នូ។ បើយើងសង្កេតទៅលើខ្សែកោងនៃឆ្នាំដទៃទៀត ដូចជាឆ្នាំ ២០១១ ២០១២ ២០១៣ ២០១៤ និង ២០១៥ បានបង្ហាញយ៉ាងជាក់ស្តែងថា នៅចុងឆ្នាំនីមួយៗគឺខែធ្នូនេះឯងតែងតែមាន ភ្ញៀវទេសចរច្រើន។ បើតាមការសន្ទត់របស់ក្រុមយើងខ្ញុំ គឺអាចបណ្តាលមកពីអាកាសធាតុត្រជាក់ល្អក៏ថាបាន។

**ក្រាហ្វិកទី២.១០ ៖ ដប់ប្រទេសដែលមានភ្ញៀវទេសចរចូលមកកាន់ប្រទេសកម្ពុជាច្រើនជាងគេឆ្នាំ២០១៦**




ប្រភព៖ Statistics and Tourism Information Department, MOT2016

ក្រាបសសរដែលជាក្រាហ្វិកនេះបានបង្ហាញពី ភ្ញៀវទេសចរដែលចូលមកកាន់ប្រទេសកម្ពុជាច្រើនជាងគេទាំងដប់ប្រទេស ក្នុងនោះប្រទេសវៀតណាមមានចំនួនប្រជាជនច្រើនជាងគេ គឺរហូតដល់ទៅ 959,663 នាក់ ប្រទេសចិនជាប្រទេសដែលមានភ្ញៀវទេសចរចូលមកកាន់កម្ពុជាច្រើនបន្ទាប់ពីប្រទេសវៀតណាមគឺមាន 830,003 ថៃមាន 398,081 ឡាវមាន 369,335 កូរ៉េមាន 357,194 សហរដ្ឋអាមេរិកមាន 238,658 ជប៉ុនមាន 191,577 ចក្រភពអង់គ្លេសមាន 159,489 ម៉ាឡេស៊ីមាន 152,843 និង ប្រទេសលំដាប់ទីដប់គឺ ប្រទេសបារាំងមានភ្ញៀវទេសចរ 150,294 នាក់ចូលមកប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះក៏មានភ្ញៀវអន្តរជាតិដែលមកពីប្រទេសផ្សេងៗផងដែរគឺមានដូចជា៖ ឥណ្ឌូនេស៊ី ព្រុយណេ មីយ៉ាន់ម៉ា សិង្ហបុរី ភីលីពីន ចិនហុងកុង ចិនតៃវ៉ាន់ ឥណ្ឌា នេប៉ាល់ អូស្ត្រាលី អាហ្គានីស្ថាន បង់ក្លាដេស ប៉ាគីស្ថាន ស្រីលង្កា ដាណឺម៉ាក ន័រវេ អាឡឺម៉ង់ ស្វីស ឡុចស៊ីមបួរ រុស្ស៊ី....។

**ក្រាបទី២.១១ ៖ ភាគរយនៃភ្ញៀវទេសចរក្នុងឆ្នាំ២០១៦**




ប្រភព៖ Statistics and Tourism Information Department, MOT2016

ក្រាបនេះបង្ហាញឲ្យឃើញពីភាគរយនៃភ្ញៀវទេសចរតំណាងឲ្យប្រទេស នីមួយៗដែលចូលមកធ្វើដំណើរទេសចរណ៍ក្នុងប្រទេសកម្ពុជាយើងក្នុងឆ្នាំ២០១៦។ យើងឃើញថាក្នុងចំណោមភ្ញៀវទេសចរទាំងអស់ដែលចូលមកកាន់ប្រទេសកម្ពុជា ភ្ញៀវទេសចរដែលមកពីប្រទេសវៀតណាមគឺស្ថិតក្នុងលំដាប់ថ្នាក់ទី១ គឺបានក្តោបក្តាប់ ប្រមាណជា ១៩.១% នៃចំនួនភ្ញៀវទេសចរសរុប រីឯលំដាប់ថ្នាក់ទី២គឺប្រទេសចិន បានក្តោបប្រមាណ ១៦.៦% និង ចំណាត់ថ្នាក់បន្តបន្ទាប់ទៀតនោះគឺប្រទេសថៃ ៧.៩% ឡាវ ៧.៤% កូរ៉េ សហរដ្ឋអាមេរិក ៤.៨% ជប៉ុន ៣.៨% ចក្រភពអង់គ្លេស ៣.២% ម៉ាឡេស៊ី ៣% បារាំង៣% និង ប្រទេសជាច្រើនដទៃទៀតប្រមាណ ២៤.១%។

**តារាងទី២.៣ ៖ មធ្យោបាយធ្វើដំណើរក្នុងការចូលមកកាន់កម្ពុជា**

| មធ្យោបាយធ្វើដំណើរ | 2016 |
|---|---|
| **ផ្លូវអាកាស** | **2,704,367** |
| ព្រលានយន្តហោះភ្នំពេញអន្តរជាតិ | 1,164,240 |

| | |
|---|---|
| ព្រលានយន្តហោះសៀមរាបអន្តរជាតិ | 1,507,039 |
| កោះកេង | 33,088 |
| **ផ្លូវគោក និង ផ្លូវទឹក** | **2,307,345** |
| ផ្លូវគោក | 2,153,932 |
| ផ្លូវទឹក | 153,413 |
| **សរុប** | **5,011,712** |

ប្រភព៖ របាយការណ៍ស្ថិតិទេសចរ២០១៦

តារាងខាងលើនេះបង្ហាញពីមធ្យោបាយ នៃការធ្វើដំណើរមកកាន់ប្រទេសកម្ពុជារបស់ភ្ញៀវទេសចអន្តរជាតិក្នុងឆ្នាំ ២០១៦។ ដោយបង្ហាញថាភ្ញៀវទេសចរបានធ្វើដំណើរតាមព្រលានយន្តហោះអន្តរជាតិភ្នំពេញមានចំនួន ១,១៦៤,២៤០នាក់ តាមព្រលានយន្តហោះសៀមរាបអន្តរជាតិមានចំនួន ១,៥០៧,០៣៩ នាក់ តាមព្រលានយន្តហោះកោះកេងចំនួន ៣៣,០៨៨នាក់ ជាសរុប ការធ្វើដំណើរតាមផ្លូវអាកាសរបស់ភ្ញៀវទេសចរអន្តរជាតិគឺមាន ២,៧០៤,៣៦៧។ រីឯភ្ញៀវទេសចរដែលធ្វើដំណើរតាមផ្លូវគោក មានចំនួន ២,១៥៣,៩៣២ និង តាមផ្លូវទឹកមានចំនួន ១៥៣,៤១៣ នាក់។

**២.២.១.២. ស្ថិតិទេសចរ** Outbound

ទេសចរ Outbound សំដៅទៅភ្ញៀវទេសចរជាតិទាំងឡាយណាដែលធ្វើដំណើរទៅកាន់ប្រទេសដទៃទៀត។ ខាងក្រោមជាទិន្នន័យនានាដែលនិយាយពី Outbound Tourism។

**តារាងទី២.៤ ៖ Outbound Tourist**

| | **2016** |
|---|---|
| Cambodia Outbound Tourists | 1,434,030 |
| International Tourist Departure | 4,473,314 |

ប្រភព៖របាយការណ៍ស្ថិតិទេសចរ ២០១៦

តាមតារាងបង្ហាញឲ្យឃើញថា ភ្ញៀវទេសចរកម្ពុជាបានចេញដំណើរទៅកាន់បរទេសប្រមាណជាង ១,៤៣៤,០៣០ នាក់ក្នុងឆ្នាំ២០១៦នេះ។ កើនឡើងប្រមាណ២០.១% បើធៀបនឹងឆ្នាំមុន ដែលមានត្រឹមតែ ១,១៩៤,០៨១។[24] នេះអាចបង្ហាញឲ្យឃើញយ៉ាងច្បាស់អំពី កម្រិតជីវភាពដ៏ល្អប្រសើររបស់ប្រជាពលរដ្ឋកម្ពុជាពីមួយឆ្នាំទៅមួយឆ្នាំ។

[24] Statistic and Tourism Information Department, MOT

# ជំពូកទី៣
# ការវិភាគពីទំនាក់ទំនងនៃ
# វិស័យទេសចរណ៍ និង
# កំណើនសេដ្ឋកិច្ច

# ជំពូកទី៣

## ការវិភាគពីទំនាក់ទំនងនៃវិស័យទេសចរណ៍ និង កំណើនសេដ្ឋកិច្ច

### ៣.១. ផលិតផលក្នុងស្រុកសរុប (GDP)

ក្រាប៣.១. ក្រាបបង្ហាញពីកំណើននៃផលិផលក្នុងស្រុកសរុប (GDP)




<u>ប្រភព៖ ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ២០១៦</u>

ក្រាហ្វិកខាងលើ បានបង្ហាញ GDP នៃប្រទេសកម្ពុជាចាប់ពីឆ្នាំ ២០០៧ ដល់ ២០១៦។ ដោយសង្កេតឃើញថាចំណូលផលិតផលសរុបមានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយក្នុងឆ្នាំ ២០០៧ GDP របស់កម្ពុជាមានត្រឹមតែ ១០.២% ។ ហើយក្នុងឆ្នាំ ២០០៨ កំណើននៅតែបន្តកើនឡើង គ្រាន់តែស្ថិតក្នុងកំណើនទាប ត្រឹមតែ៦.៧% បើធៀបនឹងឆ្នាំ ២០០៧ រីឯក្នុងឆ្នាំ ២០០៩ កំណើននៃសេដ្ឋកិច្ចធ្លាក់ខ្លាំងមកត្រឹមតែ ០.១% ប៉ុណ្ណោះ។ តែក្នុងឆ្នាំ ២០១០ សេដ្ឋកិច្ចមានកំណើនខ្លាំងឡើងវិញ ដល់ទៅ ៦% ហើយចាប់ពីឆ្នាំ ២០១១ រហូតដល់ឆ្នាំ ២០១៦នេះ កំណើននៃសេដ្ឋកិច្ចកម្ពុជា រក្សាលំនឹងបានល្អ គឺក្នុងអត្រាប្រមាណជាង ៧%។

## ៣.២.កំណើននៃទេសចរណ៍

យើងដឹងហើយថា បើកាលណាភ្ញៀវទេសចរកើនឡើង នោះនឹងធ្វើឲ្យវិស័យទេសចរណ៍កើនឡើងដែរ ដូចនេះក្រាបខាងក្រោមនឹងធ្វើការបង្ហាញអំពីកំណើននៃទេសចរ ដែលកម្ពុជាទទួបាន តាំងពីឆ្នាំ ២០០៧មក ចង់ដឹងថាតើចាប់ពីឆ្នាំ ២០០៧ ដល់ ឆ្នាំ២០១៦ កម្ពុជាទទួលបានកំណើននៃទេសចរប៉ុន្មានភាគរយ សូមមើលទៅក្រាបខាងក្រោមនេះ៖

**ក្រាបទី៣.២. ក្រាបបង្ហាញពីកំណើននៃទេសចរ**




ប្រភព៖ ក្រសួងទេសចរណ៍ ២០១៧

នេះគឺជាកំណើននៃភ្ញៀវទេសចររបស់កម្ពុជាយើងចាប់តាំងពី ឆ្នាំ ២០០៧ ដល់ ឆ្នាំ ២០១៦ ដោយយើងសង្កេតឃើញថាក្នុងឆ្នាំ ២០១២ កំណើននៃភ្ញៀវទេសចរមានកំណើនខ្ពស់ខ្លាំង រហូតដល់ទៅ ២៤.៤% ឯណោះ បើធៀបនឹងឆ្នាំមុន ប៉ុន្តែយ៉ាងណា យើងបានឃើញថាក្នុងឆ្នាំបន្តបន្ទាប់កំណើននៃភ្ញៀវទេសចរហាក់មានកំណើនមិនសូវខ្ពស់ដូចឆ្នាំ ២០១២ នោះឡើយ។ ដូចជាក្នុងឆ្នាំ ២០១៣ កំណើននៃភ្ញៀវទេសចរមានត្រឹមតែ ១៧.៥% ហើយបន្តធ្លាក់ចុះមកត្រឹម ៧% ក្នុងឆ្នាំ ២០១៤ រីឯឆ្នាំ ២០១៥ កំណើនមានត្រឹមតែ ៦.១% ហើយក្នុងឆ្នាំ២០១៦ ដែលទើបតែកន្លងហួសទៅ

ថ្មីៗមានត្រឹម ៥%។ យ៉ាងណាក៏ដោយ ការធ្លាក់ចុះនៃកំណើនមិនមែនមានន័យថាចំនួននៃភ្ញៀវទេសចរធ្លាក់ចុះនោះទេ គ្រាន់តែការកើនឡើងនៃភ្ញៀវទេសចរមានកម្រិតទាបតែប៉ុណ្ណោះ។

## ៣.៣. ទំនាក់ទំនងនៃវិស័យទេសចរណ៍ក្នុងសេដ្ឋកិច្ចជាតិ

ខាងក្រោមនឹងបង្ហាញអំពីទំនាក់ទំនង រវាងវិស័យទេសចរណ៍ និង សេដ្ឋកិច្ចកម្ពុជា។ តើវិស័យទេសចរណ៍មានឥទ្ធិពលទៅលើសេដ្ឋកិច្ចដែរឬទេសូមមើលមកកាន់ក្រាបខាងក្រោមនេះ។

**ក្រាបទី ៣.៣. ក្រាបបង្ហាញពីទំនាក់ទំនងនៃកំណើនទេសចរ និងកំណើនសេដ្ឋកិច្ច**




ក្រាបនេះបានបង្ហាញឲ្យឃើញពីទំនាក់ទំនងនៃ វិស័យទេសចរណ៍ និង សេដ្ឋកិច្ចកម្ពុជាពីឆ្នាំ ២០១១ ដល់ ២០១៦ ថាពិតជាមានភាពទាក់ទងគ្នា មានន័យថាវិស័យទេសចរណ៍គឺជាផ្នែកមួយក្នុងសេដ្ឋកិច្ច ព្រោះបើវិស័យទេសចរណ៍រីកចម្រើន នោះនឹងធ្វើឲ្យសេដ្ឋកិច្ចរីកចម្រើនដែរ។

យោងតាមការបញ្ចូលទិន្នន័យទៅក្នុង កម្មវិធី Excel ដើម្បីវិភាគនូវទិន្នន័យដែលទទួលបានខាងលើ បង្ហាញឲ្យនូវសមីការដូចខាងក្រោមនេះ :

$$Y = 4.497 + 0.196X$$

Y: GDP Growth Rate

X: Tourism Growth Rate

$$=> \frac{dy}{dx} = (Y = 4.497 + 0.196X)' = 0.196$$

$Y_x' = 0.194 > 0$ មានន័យថាកាលណាទេសចរណ៍កើននោះនឹងធ្វើឲ្យ $GDP$ កើនដែរ

រកភាពយឺតនៃវិស័យទេសចរណ៍ $e_x = \frac{X_0}{D(X_0)} \times D'(X_0) = \frac{5\%}{7\%} \times 0.196 = 0.14\%$

នេះបានបញ្ជាក់ថា កាលណាទេសចរណ៍កើនឡើង 1% នោះ GDP រំពឹងថានឹងកើនបាន 0.14% ពីកំណើននៃទេសចរ។ សរុបសេចក្តីមក វិស័យទេសចរណ៍ពិតជាមានឥទ្ធិពលវិជ្ជមានទៅក្នុងកំណើនសេដ្ឋកិច្ចជាតិ។

# សន្និដ្ឋាន និង អនុសាសន៍

# សេចក្តីសន្និដ្ឋាន និង អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

កំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាទទួលបានកំណើនខ្ពស់ ជាពិសេសក្នុងរយៈប៉ុន្មានឆ្នាំចុងក្រោយនេះ ដែលត្រូវបានចូលរួមពីវិស័យសំខាន់ៗជាច្រើននៅក្នុងប្រទេស។ វិស័យទេសចរណ៍ក៏មានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួម ដើម្បីជម្រុញឲ្យមានកំណើនសេដ្ឋកិច្ចផងដែរ។ ទេសចរណ៍កម្ពុជាបានរីកចម្រើនពី មួយឆ្នាំទៅមួយឆ្នាំ ដោយសារតែមានការអភិវឌ្ឍន៍នូវតំបន់ទេសចរណ៍ជាច្រើនក្នុងប្រទេសកម្ពុជា ដូចជាតំបន់ទេសចរណ៍វប្បធម៌ និង តំបន់អេកូទេសចរណ៍ជាដើម។ ហេតុផលនេះហើយទើបធ្វើឲ្យភ្ញៀវទេសចរអន្តរជាតិ បានចូលមកទស្សនាប្រទេសកម្ពុជាកាន់តែច្រើនឡើងៗ ពីមួយឆ្នាំទៅមួយឆ្នាំ។ ដោយសារតែការកើននៃចំនួនភ្ញៀវទេសចរដូច្នេះហើយទើបចំណូលដែលយើងទទួលបានពីវិស័យទេសចរណ៍កាន់តែច្រើនឡើងៗ ដែលជាកត្តាជម្រុញឲ្យកំណើនសេដ្ឋកិច្ចកើនឡើង។

ការកើនឡើងនូវនៃភ្ញៀវទេសចរនៅក្នុងប្រទេសកម្ពុជា បានជះឥទ្ធិពលវិជ្ជមានមកលើជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និង សេដ្ឋកិច្ចគ្រួសាររបស់ពួកគេ ព្រោះពួកគេអាចលក់នូវផលិតផល ធ្វើដោយដៃលក្ខណៈគ្រួសារយកទៅលក់ ជូនភ្ញៀវបរទេសនានា ហើយវាជាផ្នែកមួយក្នុងការលើកស្ទួយនូវជីវភាពគ្រួសាររបស់ពួកគាត់ថែមមួយកម្រិតទៀត។ ម៉្យាងវិញទៀតវិស័យទេសចរណ៍គឺជាវិស័យមួយដែលស្រូបយកកម្លាំងពលកម្ម ក្នុងប្រទេសមួយភាគធំ ឲ្យមានការងារធ្វើតាមរយៈការបើក ជាកន្លែងកម្សាន្ត ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ សេវាកម្មដឹកជញ្ជូន ដូចជា ឡានក្រុង ឡានតាក់ស៊ី តុកតុក ជាពិសេសគឺ ជើងហោះហើរ -ល- ។ ហើយថ្មីៗនេះមានក្រុមហ៊ុនអាកាសចរណ៍ជាច្រើនដែលបានបើកក្រុមហ៊ុនក្នុងប្រទេសកម្ពុជា មិនត្រឹមតែប៉ុណ្ណោះ មានក្រុមហ៊ុន បរទេសមួយចំនួនបានបើកជើងហោះហើរផ្ទាល់ ពីប្រទេសរបស់ខ្លួនមកកាន់កម្ពុជា ដូចជាប្រទេសជប៉ុន និង ប្រទេសឥណ្ឌាជាដើម។ ម៉្យាងទៀតវិស័យនេះក៏បានផ្តល់នូវប្រយោជន៍ជូនរដ្ឋតាមរយៈការកាត់ពន្ធប្រាក់ចំនេញពីក្រុមហ៊ុនដែលយើងបានធ្វើការរៀបរាប់រួចមកហើយនេះ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយបញ្ហាពាក់ព័ន្ធ ក៏នៅតែមានកើតមានឡើងបន្តិចបន្តួច ដោយសារតែមានការត្អូញត្អែរពីសំណាក់ភ្ញៀវជាតិ និង អន្តរជាតិ ជាច្រើនអំពី បរិស្ថានជុំវិញហាក់ដូចជាមិនសូវជាមានអនាម័យល្អ និង តម្លៃម្ហូបអាហារព្រមទាំងកន្លែងស្នាក់នៅក៏ឡើងថ្លៃខ្លាំង ពេលដែលមានពិធីបុណ្យទានម្តងៗ ។ ចំណែកឯតំបន់ទេសចរណ៍ផ្សេងៗទៀតពុំមានបង្គន់អនាម័យគ្រប់គ្រាន់នោះ

ទេ។ ចំនុចខ្វះខាតតិចតួចនេះអាចជះឥទ្ធិពលដល់រយៈពេលស្នាក់នៅរបស់ភ្ញៀវទេសចរ ហើយក៏អាចជះឥទ្ធិពលដល់កំណើននៃភ្ញៀវទេសចរនៅឆ្នាំបន្តបន្ទាប់ផងដែរ។

## ២. អនុសាសន៍

ជាការពិតណាស់ការរីកលូតលាស់នៃវិស័យទេសចរណ៍ក្នុងប្រទេសកម្ពុជា បានផ្តល់នូវសារៈប្រយោជន៍យ៉ាងច្រើន ទៅលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាសេដ្ឋកិច្ចក្នុងប្រទេសទាំងមូល។ ទន្ទឹមនឹងប្រយោជន៍នៃវិស័យទេសចរណ៍ចំពោះសេដ្ឋកិច្ចកម្ពុជា វិស័យនេះក៏បានកើតមាននូវបញ្ហាមួយចំនួនផងដែរ ដែលរាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់ដោះស្រាយ ដើម្បីអភិវឌ្ឍន៍វិស័យទេចរណ៍ និង ទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត ខាងក្រោមជាអនុសាសន៍មួយចំនួនសម្រាប់ដោះស្រាយបញ្ហាដែលពួកយើងបានរៀបរាប់រួចមកហើយៈ

រាជរដ្ឋាភិបាលគួរតែយកចិត្តទុកដាក់បន្ថែមចំពោះការថែរក្សាអនាម័យ ក្នុងតំបន់ទេសចរណ៍នានា ដោយត្រូវកំណត់កន្លែងចោលសំរាមឲ្យច្បាស់លាស់ ដើម្បីមានងាយស្រួលដល់ អ្នកដែលត្រូវយកសំរាមទៅចោល បន្ថែមធុងសំរាមទៅតាមកន្លែងទេសចរណ៍នានា ដើម្បីឲ្យភ្ញៀវទេសចរងាយស្រួលក្នុងការស្វែងរក។ មិនតែប៉ុណ្ណោះត្រូវប្រមូលសំរាមចេញពីធុងឲ្យបានញឹកញប់ ជៀសវាងសំរាមពេញធុង នឹងធ្លាក់ចេញមកក្រៅជាហេតុធ្វើឲ្យបរិស្ថានកខ្វក់។

រីឯភោជនីយដ្ឋានត្រូវធ្វើការណែនាំដល់ ម្ចាស់ភោជនីយដ្ឋាននីមួយៗឲ្យធ្វើការកំណត់តម្លៃអាហារ និង ទំនិញផ្សេងៗ ឲ្យបានច្បាស់ ហើយចៀសវាងការឡើងថ្លៃខ្ពស់ពេកក្នុងរដូវបុណ្យទាននានា ហើយអ្វីដែលពិសេសគឺអនាម័យទៅលើម្ហូបអាហារ។ ចំណែកឯមធ្យោបាយធ្វើដំណើរ និងកន្លែងស្នាក់នៅក៏ដូចគ្នាដែរ មិនត្រូវឲ្យពួកគាត់តម្លើងថ្លៃកប់ពពកពេកនោះទេ។ ជាពិសេសនៅពេលមានពិធីបុណ្យប្រពៃណីជាតិ និង អន្តរជាតិជាដើម។

ម៉្យាងទៀត រាជរដ្ឋាភិបាលត្រូវណែនាំប្រជាពលរដ្ឋឲ្យយល់ដឹងអំពីផលប៉ះពាល់ អវិជ្ជមានចេញពីការកំណត់ថ្លៃមិនសមហេតុផល និង បញ្ហាបរិស្ថាននានា។ ពេលដែលប្រជាពលរដ្ឋបានយល់ដឹងច្បាស់ហើយនោះបញ្ហានឹងត្រូវបានដោះស្រាយ និង មិនមានការព្រួយបារម្ភពីបញ្ហាទាំងនេះទៀតឡើយ៕

# ឯកសារយោង

# ឯកសារយោង

- ❖ **ឯកសារយោងជាភាសាខ្មែរ**


បណ្ឌិត ឈុន ពហុ, អនុបណ្ឌិត ជា ស៊ីថា, ហុង វណ្ណៈ និង សាំង ចន្ទ. ឆ្នាំ ២០១៤ “*សេចក្តីផ្តើមទេសចរណ៍*“

សាស្ត្រាចារ្យ ម៉ម ចរិយាវុធ និង សាស្ត្រាចារ្យ ងួន ហេង, “*សេដ្ឋកិច្ចនយោបាយ*” ,បោះពុម្ពលើកទី៣,ឆ្នាំ២០១២,ទំព័រ ១១៣-១១៤

របាយការណ៍ស្ថិតិទេសចរណ៍(២០១៧)

ក្រសួងសេដ្ឋកិច្ច និង ហរិញ្ញវត្ថុ២០១៦ និង ២០១៧


- ❖ **ឯកសារយោងជាភាសាបរទេស**


https://en.wikipedia.org/wiki/Economy_of_Thailand(07/05/2017)

https://knoema.com/atlas/thailand/topics/tourism/travel-and-tourism-total-contribution-to-gdp/total-contri...(07/05/2017)

https://knoema.com/atlas/thailand/topics/tourism/travel-and-tourism-total-contribution-to-gdp/total-contribut... *(24/មេសា/២០១៧)*

https://en.wikipedia.org/wiki/Tourism_in_Singapore *(២៤/មេសា/២០១៧)*

https://www.travelchinaguide.com/tourism/ *(២៥/មេសា/២០១៧)*

https://en.wikipedia.org/wiki/Economy_of_Laos(07/05/2017)

https://en.wikipedia.org/wiki/Tourism_in_the_Philippines *(២៥/មេសា/២០១៧)*

www.investopedia.com/terms/e/economicgrowth.asp

(http://www.investopedia.com /term/c/classicaleconomics.asp)

http://www.wisegeek.com/what-are-the-different-theories-of-economic-growth.htm) ០៧/០៦/២០១៧

*https://www.allaboutcareers.com/careers/industry/hospitality-tourism (០៨/០៧/២០១៧)*

https://www.adamsmith.org *(08/07/2017)*

*ww.econlib.org>library>Enc>bios ( 08/07/2017)*

*http://www.econ.nyu.edu(08/07/2017)*

*htttp://en.m.wikipedia.org (08/07/2017)*

*https:// sites.sas.upenn.edu (08/07/2017)*

# ឧបសម្ព័ន្ធទី១

# ឧបសម្ព័ន្ធទី១៖

SUMMARY OUTPUT

| *Regression Statistics* | |
|---|---|
| Multiple R | 0.584404 |
| R Square | 0.341528 |
| Adjusted R Square | 0.259219 |
| Standard Error | 2.176041 |
| Observations | 10 |

ANOVA

| | *df* | *SS* | *MS* | *F* | *Significance F* |
|---|---|---|---|---|---|
| Regression | 1 | 19.6478 | 19.6478 | 4.14934 | 0.07603 |
| Residual | 8 | 37.8812 | 4.73515 | | |
| Total | 9 | 57.529 | | | |

| | *Coefficients* | *Standard Error* | *t Stat* | *P-value* | *Lower 95%* | *Upper 95%* | *Lower 95.0%* | *Upper 95.0%* |
|---|---|---|---|---|---|---|---|---|
| Intercept | 4.497046 | 1.23661 | 3.63658 | 0.00662 | 1.64541 | 7.348684 | 1.645408 | 7.348684 |
| X Variable 1 | 0.196245 | 0.09634 | 2.03699 | 0.07603 | -0.02592 | 0.418407 | -0.02592 | 0.418407 |

RESIDUAL OUTPUT

| *Observation* | *Predicted Y* | *Residuals* |
|---|---|---|
| 1 | 8.133468 | 2.06653 |
| 2 | 5.572469 | 1.12753 |
| 3 | 4.830663 | -4.7307 |
| 4 | 5.682366 | 0.31763 |
| 5 | 7.421098 | -0.3211 |
| 6 | 9.285427 | -1.9854 |
| 7 | 7.931335 | -0.5313 |
| 8 | 5.870762 | 1.22924 |
| 9 | 5.694141 | 1.30586 |
| 10 | 5.478271 | 1.52173 |

# ឧបសម្ព័ន្ធទី២

KINGDOM OF CAMBODIA
NATION RELIGION KING

# TOURISM STATISTICS REPORT

# Year 2016

**MINISTRY OF TOURISM**
Statistics and Tourism Information Department
No. A3, Street 169, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia.
Fax: +855 23 885003
E-mail: kong@mot.gov.kh
Web site: www.mot.gov.kh

## Tourism Highlights

**Int'l Tourist Arrivals, Average Length of Stays, Hotel Occupancy & Int'l Tourism Receipts 1993 - 2016**

| Years | Int'l Tourist Arrivals | | Average Length | Hotel Occupancy | Tourism Receipts |
|---|---|---|---|---|---|
| | Number | Change (%) | of Stays (Days) | (%) | (Million US$) |
| 1993 | 118,183 | - | N/A | N/A | N/A |
| 1994 | 176,617 | 49.4 | N/A | N/A | N/A |
| 1995 | 219,680 | 24.4 | 8.00 | 37.0 | 100 |
| 1996 | 260,489 | 18.6 | 7.50 | 40.0 | 118 |
| 1997 | 218,843 | -16.0 | 6.40 | 30.0 | 103 |
| 1998 | 286,524 | 30.9 | 5.20 | 40.0 | 166 |
| 1999 | 367,743 | 28.3 | 5.50 | 44.0 | 190 |
| 2000 | 466,365 | 26.8 | 5.50 | 45.0 | 228 |
| 2001 | 604,919 | 29.7 | 5.50 | 48.0 | 304 |
| 2002 | 786,524 | 30.0 | 5.80 | 50.0 | 379 |
| 2003 | 701,014 | -10.9 | 5.50 | 50.0 | 347 |
| 2004 | 1,055,202 | 50.5 | 6.30 | 52.0 | 578 |
| 2005 | 1,421,615 | 34.7 | 6.30 | 52.0 | 832 |
| 2006 | 1,700,041 | 19.6 | 6.50 | 54.8 | 1,049 |
| 2007 | 2,015,128 | 18.5 | 6.50 | 54.8 | 1,400 |
| 2008 | 2,125,465 | 5.5 | 6.65 | 62.7 | 1,595 |
| 2009 | 2,161,577 | 1.7 | 6.45 | 63.6 | 1,561 |
| 2010 | 2,508,289 | 16.0 | 6.45 | 65.7 | 1,786 |
| 2011 | 2,881,862 | 14.9 | 6.50 | 66.2 | 1,912 |
| 2012 | 3,584,307 | 24.4 | 6.30 | 68.5 | 2,210 |
| 2013 | 4,210,165 | 17.5 | 6.75 | 69.5 | 2,547 |
| 2014 | 4,502,775 | 7.0 | 6.50 | 67.6 | 2,736 |
| 2015 | 4,775,231 | 6.1 | 6.80 | 70.2 | 3,012 |
| 2016 | 5,011,712 | 5.0 | 6.30 | 68.9 | 3,212 |

**International Tourist Arrivals to Cambodia**

| Months | 2011 | 2012 | 2013 | 2014 | 2015 | 2016 | Change (%) | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | 12/11 | 13/12 | 14/13 | 15/14 | 16*/15 |
| **Q1** | **778,467** | **995,210** | **1,172,072** | **1,267,922** | **1,307,836** | **1,342,477** | **27.8** | **17.8** | **8.2** | **3.1** | **2.6** |
| January | 274,471 | 350,257 | 404,106 | 442,045 | 460,577 | 466,086 | 27.6 | 15.4 | 9.4 | 4.2 | 1.2 |
| February | 255,499 | 321,870 | 385,760 | 425,801 | 430,207 | 448,468 | 26.0 | 19.8 | 10.4 | 1.0 | 4.2 |
| March | 248,497 | 323,083 | 382,206 | 400,076 | 417,052 | 427,923 | 30.0 | 18.3 | 4.7 | 4.2 | 2.6 |
| **Q2** | **606,562** | **761,442** | **920,527** | **933,446** | **994,154** | **1,018,455** | **25.5** | **20.9** | **1.4** | **6.5** | **2.4** |
| April | 223,032 | 277,304 | 327,000 | 332,690 | 361,139 | 367,684 | 24.3 | 17.9 | 1.7 | 8.6 | 1.8 |
| May | 190,258 | 233,220 | 292,115 | 300,302 | 314,748 | 320,601 | 22.6 | 25.3 | 2.8 | 4.8 | 1.9 |
| June | 193,272 | 250,918 | 301,412 | 300,454 | 318,267 | 330,170 | 29.8 | 20.1 | -0.3 | 5.9 | 3.7 |
| **Q3** | **699,760** | **820,888** | **964,612** | **998,690** | **1,044,880** | **1,147,483** | **17.3** | **17.5** | **3.5** | **4.6** | **9.8** |
| July | 239,527 | 284,282 | 338,761 | 340,091 | 364,325 | 395,761 | 18.7 | 19.2 | 0.4 | 7.1 | 8.6 |
| August | 250,429 | 293,859 | 342,064 | 347,211 | 366,096 | 406,214 | 17.3 | 16.4 | 1.5 | 5.4 | 11.0 |
| September | 209,804 | 242,747 | 283,787 | 311,388 | 314,459 | 345,508 | 15.7 | 16.9 | 9.7 | 1.0 | 9.9 |
| **Q4** | **797,073** | **1,006,767** | **1,152,954** | **1,302,717** | **1,428,361** | **1,503,297** | **26.3** | **14.5** | **13.0** | **9.6** | **5.2** |
| October | 233,190 | 290,959 | 334,410 | 390,637 | 408,922 | 414,077 | 24.8 | 14.9 | 16.8 | 4.7 | 1.3 |
| November | 265,539 | 333,482 | 386,737 | 411,501 | 444,640 | 477,686 | 25.6 | 16.0 | 6.4 | 8.1 | 7.4 |
| December | 298,344 | 382,326 | 431,807 | 500,579 | 574,799 | 611,534 | 28.1 | 12.9 | 15.9 | 14.8 | 6.4 |
| **Total** | **2,881,862** | **3,584,307** | **4,210,165** | **4,502,775** | **4,775,231** | **5,011,712** | **24.4** | **17.5** | **7.0** | **6.1** | **5.0** |




*Source: Statistics and Tourism Information Department, MOT*

## CAMBODIA: TOURISM STATISTICS REPORT IN 2016

### I. INBOUND TOURISM

1. International tourist arrivals in January - December 2016

| | Inbound tourism | | Share (%) | | Change (%) |
|---|---|---|---|---|---|
| | 2015 | 2016 | 2015 | 2016 | 2016*/15 |
| **Air** | **2,476,001** | **2,704,367** | **51.9** | **54.0** | **9.2** |
| Phnom Penh Int'l Airport (PNH) | 1,061,034 | 1,164,240 | 22.2 | 23.2 | 9.7 |
| Siem Reap Int'l Airport (REP) | 1,414,967 | 1,507,039 | 29.6 | 30.1 | 6.5 |
| Kong Keng (KOS) | | 33,088 | | 0.7 | |
| **Land and Waterways** | **2,299,230** | **2,307,345** | **48.1** | **46.0** | **0.4** |
| Land | 2,151,138 | 2,153,932 | 45.0 | 43.0 | 0.1 |
| Waterways | 148,092 | 153,413 | 3.1 | 3.1 | 3.6 |
| **Total** | **4,775,231** | **5,011,712** | **100.0** | **100.0** | **5.0** |

2. Top ten markets arrivals in January - December 2016




| | Vietnam | China (RPC) | Thailand | Lao PDR | Korea (ROK) | U.S.A | Japan | U.K | Malaysia | France |
|---|---|---|---|---|---|---|---|---|---|---|
| 2016 | 959,663 | 830,003 | 398,081 | 369,335 | 357,194 | 238,658 | 191,577 | 159,489 | 152,843 | 150,294 |
| 2015 | 987,792 | 694,712 | 349,908 | 405,359 | 395,259 | 217,510 | 193,330 | 154,265 | 149,389 | 145,724 |
| Share (%) | 19.1 | 16.6 | 7.9 | 7.4 | 7.1 | 4.8 | 3.8 | 3.2 | 3.0 | 3.0 |
| Change (%) | -2.8 | 19.5 | 13.8 | -8.9 | -9.6 | 9.7 | -0.9 | 3.4 | 2.3 | 3.1 |

### II. OUTBOUND TOURISM

Outbound tourism in January - December 2016

| | Outbound tourism | | Change (%) |
|---|---|---|---|
| | 2015 | 2016 | 2016*/15 |
| Cambodian Outbound Tourists | 1,194,018 | 1,434,030 | 20.1 |
| International Tourists Departure | 4,225,619 | 4,473,314 | 5.9 |

### III. INTERNAL TOURISM

Foreign visitor arrivals to the regions in January - December 2016

| | Arrivals | | Share (%) | | Change (%) |
|---|---|---|---|---|---|
| | 2015 | 2016 | 2015 | 2016 | 2016*/15 |
| Phnom Penh & Surrounding | 2,650,368 | 2,806,438 | 48.6 | 49.1 | 5.9 |
| Siem Reap Angkor | 2,124,863 | 2,205,274 | 39.0 | 38.5 | 3.8 |
| Coastal Areas | 610,458 | 643,289 | 11.2 | 11.2 | 5.4 |
| Eco-tourism Areas | 63,261 | 66,349 | 1.2 | 1.2 | 4.9 |
| **Total** | **5,448,950** | **5,721,350** | **100.0** | **100.0** | **5.0** |

*Source: Statistics and Tourism Information Department, MOT*

**International Tourist Arrivals to Cambodia by Country of Residence in January - December 2016**

*(by all means of transportation)*

| Regions | 2015 | 2016 | | | | | Share | Change |
|---|---|---|---|---|---|---|---|---|
| Country of Residence | | Purposes of Visit | | | Total | Female | (%) | (%) |
| | | Holiday | Business | Others | | | 2016* | 2016*/15 |
| **Grand Total** | **4,775,231** | **4,414,633** | **342,218** | **254,861** | **5,011,712** | **2,105,367** | **100.0** | **5.0** |
| **Asia and the Pacific** | **3,716,688** | **3,333,971** | **297,443** | **230,091** | **3,861,505** | **1,584,117** | **77.0** | **3.9** |
| **ASEAN (Southeast Asia)** | **2,097,758** | **1,807,446** | **114,369** | **199,405** | **2,121,220** | **842,702** | **42.3** | **1.1** |
| Brunei Darussalam | 852 | 1,036 | 16 | 68 | 1,120 | 449 | 0.0 | 31.5 |
| Indonesia | 43,147 | 28,848 | 13,982 | 5,941 | 48,771 | 12,395 | 1.0 | 13.0 |
| Lao PDR | 405,359 | 356,165 | 215 | 12,955 | 369,335 | 196,119 | 7.4 | -8.9 |
| Malaysia | 149,389 | 138,994 | 10,787 | 3,062 | 152,843 | 51,430 | 3.0 | 2.3 |
| Myanmar | 8,965 | 10,960 | 630 | 1,229 | 12,819 | 5,372 | 0.3 | 43.0 |
| Philippines | 84,677 | 83,994 | 11,799 | 12,239 | 108,032 | 55,514 | 2.2 | 27.6 |
| Singapore | 67,669 | 64,394 | 3,429 | 2,733 | 70,556 | 22,966 | 1.4 | 4.3 |
| Thailand | 349,908 | 343,204 | 20,734 | 34,143 | 398,081 | 132,214 | 7.9 | 13.8 |
| Vietnam | 987,792 | 779,851 | 52,777 | 127,035 | 959,663 | 366,243 | 19.1 | -2.8 |
| **Northeast Asia** | **1,408,665** | **1,310,840** | **170,123** | **19,438** | **1,500,401** | **641,436** | **29.9** | **6.5** |
| China | 694,712 | 709,436 | 109,411 | 11,156 | 830,003 | 368,631 | 16.6 | 19.5 |
| Hong Kong (China) | 14,787 | 15,519 | 234 | 227 | 15,980 | 7,078 | 0.3 | 8.1 |
| Japan | 193,330 | 164,067 | 24,108 | 3,402 | 191,577 | 73,058 | 3.8 | -0.9 |
| Korea (ROK) | 395,259 | 334,910 | 17,977 | 4,307 | 357,194 | 151,173 | 7.1 | -9.6 |
| Macau (China) | 392 | 307 | 30 | 67 | 404 | 106 | 0.0 | 3.1 |
| Mongolia | 458 | 381 | 42 | 55 | 478 | 259 | 0.0 | 4.4 |
| Taiwan (China) | 109,727 | 86,220 | 18,321 | 224 | 104,765 | 41,131 | 2.1 | -4.5 |
| **Southern Asia** | **44,890** | **44,543** | **5,302** | **5,065** | **54,910** | **15,099** | **1.1** | **22.3** |
| Afghanistan | 121 | 113 | 7 | 38 | 158 | 39 | 0.0 | 30.6 |
| Bangladesh | 2,057 | 1,253 | 387 | 211 | 1,851 | 292 | 0.0 | -10.0 |
| Bhutan | 229 | 147 | 7 | 72 | 226 | 71 | 0.0 | -1.3 |
| India | 36,671 | 38,301 | 3,467 | 4,363 | 46,131 | 13,303 | 0.9 | 25.8 |
| Nepal | 2,358 | 2,041 | 349 | 115 | 2,505 | 587 | 0.0 | 6.2 |
| Pakistan | 1,521 | 1,073 | 436 | 118 | 1,627 | 270 | 0.0 | 7.0 |
| Srilanka | 1,933 | 1,615 | 649 | 148 | 2,412 | 537 | 0.0 | 24.8 |
| **Oceania** | **157,960** | **162,676** | **7,414** | **1,743** | **171,833** | **79,700** | **3.4** | **8.8** |
| Australia | 134,748 | 139,000 | 6,259 | 1,547 | 146,806 | 68,006 | 2.9 | 8.9 |
| Fiji | 191 | 166 | 28 | 36 | 230 | 82 | 0.0 | 20.4 |
| New Zealand | 23,021 | 23,510 | 1,127 | 160 | 24,797 | 11,612 | 0.5 | 7.7 |
| Other Asia & the Pacific | 7,415 | 8,466 | 235 | 4,440 | 13,141 | 5,180 | 0.3 | 77.2 |
| **Europe** | **719,134** | **724,627** | **29,750** | **14,118** | **768,495** | **347,961** | **15.3** | **6.9** |
| **Northern Europe** | **211,657** | **205,667** | **9,474** | **2,551** | **217,692** | **93,918** | **4.3** | **2.9** |
| Denmark | 11,553 | 10,899 | 392 | 171 | 11,462 | 4,911 | 0.2 | -0.8 |
| Finland | 7,246 | 6,239 | 299 | 101 | 6,639 | 2,631 | 0.1 | -8.4 |
| Iceland | 727 | 772 | 14 | 29 | 815 | 331 | 0.0 | 12.1 |
| Ireland | 11,200 | 11,397 | 442 | 104 | 11,943 | 5,593 | 0.2 | 6.6 |
| Norway | 9,521 | 9,307 | 255 | 104 | 9,666 | 4,305 | 0.2 | 1.5 |
| Sweden | 17,145 | 16,819 | 656 | 203 | 17,678 | 7,340 | 0.4 | 3.1 |
| United Kingdom | 154,265 | 150,234 | 7,416 | 1,839 | 159,489 | 68,807 | 3.2 | 3.4 |
| **Western Europe** | **319,069** | **326,716** | **14,554** | **5,462** | **346,732** | **155,626** | **6.9** | **8.7** |
| Austria | 10,080 | 10,887 | 233 | 83 | 11,203 | 4,965 | 0.2 | 11.1 |
| Belgium | 17,452 | 16,957 | 747 | 343 | 18,047 | 7,722 | 0.4 | 3.4 |
| France | 145,724 | 139,007 | 8,628 | 2,659 | 150,294 | 68,023 | 3.0 | 3.1 |
| Germany | 94,040 | 104,637 | 2,559 | 1,588 | 108,784 | 48,875 | 2.2 | 15.7 |
| Luxembourg | 690 | 823 | 14 | 22 | 859 | 322 | 0.0 | 24.5 |
| Monaco | 89 | 55 | 5 | 18 | 78 | 15 | 0.0 | -12.4 |
| Netherlands | 29,015 | 29,107 | 1,339 | 439 | 30,885 | 13,953 | 0.6 | 6.4 |
| Switzerland | 21,979 | 25,243 | 1,029 | 310 | 26,582 | 11,751 | 0.5 | 20.9 |
| **Central / Eastern Europe** | **99,099** | **94,938** | **2,885** | **1,868** | **99,691** | **51,046** | **2.0** | **0.6** |
| Bulgaria | 1,771 | 1,723 | 40 | 74 | 1,837 | 896 | 0.0 | 3.7 |
| Czech Republic | 5,603 | 5,584 | 99 | 78 | 5,761 | 2,619 | 0.1 | 2.8 |
| Estonia | 1,952 | 1,824 | 40 | 25 | 1,889 | 821 | 0.0 | -3.2 |
| Hungary | 4,190 | 4,476 | 138 | 68 | 4,682 | 2,275 | 0.1 | 11.7 |
| Kazakhstan | 2,235 | 1,513 | 235 | 24 | 1,772 | 878 | 0.0 | -20.7 |
| Kyrgyzstan | 161 | 133 | 20 | 22 | 175 | 78 | 0.0 | 8.7 |
| Latvia | 1,081 | 962 | 38 | 23 | 1,023 | 451 | 0.0 | -5.4 |
| Lithuania | 1,861 | 2,105 | 77 | 29 | 2,211 | 1,107 | 0.0 | 18.8 |
| Poland | 14,008 | 15,541 | 256 | 115 | 15,912 | 7,888 | 0.3 | 13.6 |
| Romania | 2,414 | 2,450 | 70 | 100 | 2,620 | 1,409 | 0.1 | 8.5 |
| Russian Federation | 55,500 | 51,093 | 1,522 | 549 | 53,164 | 28,476 | 1.1 | -4.2 |
| Slovakia | 2,266 | 2,633 | 66 | 41 | 2,740 | 1,302 | 0.1 | 20.9 |
| Ukraine | 5,322 | 4,498 | 232 | 684 | 5,414 | 2,650 | 0.1 | 1.7 |
| Uzbekistan | 735 | 403 | 52 | 36 | 491 | 196 | 0.0 | -33.2 |

*Source: Statistics and Tourism Information Department, MOT*

**International Tourist Arrivals to Cambodia by Country of Residence in January - December 2016**

*(by all means of transportation)*

| Regions | 2015 | 2016 | | | | | Share | Change |
|---|---|---|---|---|---|---|---|---|
| Country of Residence | | Purposes of Visit | | | Total | Female | (%) | (%) |
| | | Holiday | Business | Others | | | 2016* | 2016*/15 |
| **Grand Total** | **4,775,231** | **4,414,633** | **342,218** | **254,861** | **5,011,712** | **2,105,367** | **100.0** | **5.0** |
| **Southern Europe** | **84,254** | **91,755** | **2,658** | **1,648** | **96,061** | **44,080** | **1.9** | **14.0** |
| Croatia | 1,304 | 1,090 | 38 | 85 | 1,213 | 541 | 0.0 | -7.0 |
| Greece | 1,595 | 1,465 | 77 | 110 | 1,652 | 680 | 0.0 | 3.6 |
| Italy | 32,177 | 34,124 | 1,186 | 484 | 35,794 | 15,458 | 0.7 | 11.2 |
| Malta | 462 | 479 | 8 | 25 | 512 | 220 | 0.0 | 10.8 |
| Portugal | 5,947 | 7,207 | 179 | 140 | 7,526 | 3,704 | 0.2 | 26.6 |
| Serbia | 863 | 732 | 35 | 285 | 1,052 | 477 | 0.0 | 21.9 |
| Slovenia | 1,257 | 1,138 | 60 | 20 | 1,218 | 568 | 0.0 | -3.1 |
| Spain | 34,847 | 39,683 | 591 | 197 | 40,471 | 19,851 | 0.8 | 16.1 |
| Turkey | 5,802 | 5,837 | 484 | 302 | 6,623 | 2,581 | 0.1 | 14.2 |
| Other Europe | 5,055 | 5,551 | 179 | 2,589 | 8,319 | 3,291 | 0.2 | 64.6 |
| **Americas** | **315,526** | **331,396** | **12,794** | **8,852** | **353,042** | **162,534** | **7.0** | **11.9** |
| **North America** | **281,472** | **288,612** | **12,233** | **6,829** | **307,674** | **140,753** | **6.1** | **9.3** |
| Canada | 56,834 | 57,595 | 2,503 | 617 | 60,715 | 28,512 | 1.2 | 6.8 |
| Mexico | 7,128 | 8,109 | 67 | 125 | 8,301 | 4,219 | 0.2 | 16.5 |
| United States | 217,510 | 222,908 | 9,663 | 6,087 | 238,658 | 108,022 | 4.8 | 9.7 |
| **Central America** | **720** | **764** | **35** | **81** | **880** | **351** | **0.0** | 22.2 |
| Costa Rica | 465 | 553 | 9 | 19 | 581 | 272 | 0.0 | 24.9 |
| Honduras | 112 | 135 | 18 | 38 | 191 | 40 | 0.0 | 70.5 |
| Jamaica | 143 | 76 | 8 | 24 | 108 | 39 | 0.0 | -24.5 |
| **South America** | **29,706** | **38,425** | **409** | **833** | **39,667** | **19,464** | **0.8** | **33.5** |
| Argentina | 7,870 | 13,380 | 55 | 62 | 13,497 | 6,654 | 0.3 | 71.5 |
| Brazil | 10,618 | 12,186 | 201 | 139 | 12,526 | 6,138 | 0.2 | 18.0 |
| Chile | 4,968 | 6,108 | 39 | 61 | 6,208 | 3,210 | 0.1 | 25.0 |
| Colombia | 2,903 | 3,405 | 66 | 39 | 3,510 | 1,746 | 0.1 | 20.9 |
| Ecuador | 560 | 569 | 14 | 29 | 612 | 298 | 0.0 | 9.3 |
| Peru | 1,060 | 1,218 | 12 | 449 | 1,679 | 647 | 0.0 | 58.4 |
| Uruguay | 1,004 | 1,131 | 10 | 25 | 1,166 | 567 | 0.0 | 16.1 |
| Venezuela | 723 | 428 | 12 | 29 | 469 | 204 | 0.0 | -35.1 |
| Other America | 3,628 | 3,595 | 117 | 1,109 | 4,821 | 1,966 | 0.1 | 32.9 |
| **Africa** | **9,238** | **8,416** | **1,498** | **1,219** | **11,133** | **4,373** | **0.2** | **20.5** |
| **North Africa** | **843** | **878** | **65** | **81** | **1,024** | **411** | **0.0** | **21.5** |
| Morocco | 505 | 430 | 50 | 29 | 509 | 212 | 0.0 | 0.8 |
| Sudan | 131 | 94 | 3 | 26 | 123 | 25 | 0.0 | -6.1 |
| Tunisia | 207 | 354 | 12 | 26 | 392 | 174 | 0.0 | 89.4 |
| **Subsaharan Africa** | **7,542** | **6,650** | **1,378** | **853** | **8,881** | **3,544** | **0.2** | **17.8** |
| Cameroon | 202 | 90 | 15 | 15 | 120 | 36 | 0.0 | -40.6 |
| Congo | 107 | 74 | 9 | 27 | 110 | 32 | 0.0 | 2.8 |
| Ghana | 93 | 100 | 16 | 74 | 190 | 41 | 0.0 | 104.3 |
| Kenya | 344 | 344 | 30 | 43 | 417 | 202 | 0.0 | 21.2 |
| Liberia | 55 | 29 | 2 | 15 | 46 | 8 | 0.0 | -16.4 |
| Nigeria | 1,069 | 625 | 841 | 41 | 1,507 | 141 | 0.0 | 41.0 |
| South Africa | 5,336 | 5,036 | 423 | 284 | 5,743 | 2,856 | 0.1 | 7.6 |
| Tanzania | 93 | 120 | 8 | 295 | 423 | 70 | 0.0 | 354.8 |
| Uganda | 121 | 113 | 6 | 16 | 135 | 59 | 0.0 | 11.6 |
| Zimbabwe | 122 | 119 | 28 | 43 | 190 | 99 | 0.0 | 55.7 |
| Other Africa | 853 | 888 | 55 | 285 | 1,228 | 418 | 0.0 | 44.0 |
| **Middle East** | **14,645** | **16,223** | **733** | **581** | **17,537** | **6,382** | **0.3** | **19.7** |
| Egypt | 587 | 606 | 61 | 29 | 696 | 201 | 0.0 | 18.6 |
| Iran | 525 | 532 | 34 | 34 | 600 | 180 | 0.0 | 14.3 |
| Iraq | 169 | 154 | 14 | 35 | 203 | 24 | 0.0 | 20.1 |
| Israel | 9,557 | 10,885 | 241 | 54 | 11,180 | 4,911 | 0.2 | 17.0 |
| Jordan | 340 | 789 | 213 | 28 | 1,030 | 210 | 0.0 | 202.9 |
| Kuwait | 916 | 686 | 9 | 33 | 728 | 54 | 0.0 | -20.5 |
| Oman | 214 | 193 | 2 | 17 | 212 | 40 | 0.0 | -0.9 |
| Palestine | 84 | 80 | 7 | 16 | 103 | 28 | 0.0 | 22.6 |
| Qatar | 117 | 64 | 6 | 17 | 87 | 18 | 0.0 | -25.6 |
| Saudi Arabia | 307 | 298 | 18 | 33 | 349 | 39 | 0.0 | 13.7 |
| Syria | 260 | 544 | 65 | 20 | 629 | 156 | 0.0 | 141.9 |
| United Arab Emirates | 367 | 307 | 6 | 20 | 333 | 116 | 0.0 | -9.3 |
| Yemen | 452 | 276 | 13 | 23 | 312 | 51 | 0.0 | -31.0 |
| Other Middle East | 750 | 809 | 44 | 222 | 1,075 | 354 | 0.0 | 43.3 |

*Source: Statistics and Tourism Information Department, MOT*

# ឧបសម្ព័ន្ធទី៣

# ២. ដល់ណា ?

# ខ. ការអភិវឌ្ឍសេដ្ឋកិច្ច

## ខ.១. សេដ្ឋកិច្ចកម្ពុជាបន្តរក្សាកំណើនខ្ពស់ ប៉ុន្តែតម្រូវឱ្យមានការពន្លឿនការកែទម្រង់រចនាសម្ព័ន្ធ...




**វិស័យនាំមុខកំណើន**

*ទី១. កាត់ដេរ*
(ការរួមចំណែកដល់កំណើន ១,៥១%)

*ទី២. សំណង់*
(ការរួមចំណែកដល់កំណើន ១,១៥%)

*ទី៣. វិស័យផលិតកម្មក្នុងស្រុកមិនមែនកាត់ដេរ*
(ការរួមចំណែកដល់កំណើន ០,៧៧%)

ប្រភព: វិទ្យាស្ថានជាតិស្ថិតិ, ២០១៦
សម្គាល់: ២០១៦ - ២០១៩ ជាការព្យាករបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៦